ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# បទប្បញ្ញត្តិរៀបចំអង្គការគយ

# CUSTOMS ORGANIC REGULATIONS

បោះពុម្ពលើកទី ១
First Edition

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

## សាធារណរដ្ឋប្រជាមានិតកម្ពុជា
### ឯករាជ្យ សន្តិភាព សុភមង្គល

ភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ ១៩៧៩

## សេចក្តីសំរេចចិត្ត

របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីអំពីការបង្កើតអង្គការរដ្ឋាករគយកម្ពុជា ។ ប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ។

តាមសេចក្តីស្នើរបស់លោក សមាជិកក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ទទួលបន្ទុកក្រសួងពាណិជ្ជកម្ម ។

- ផ្អែកតាមមាត្រាទី... នៃកម្មវិធីសកម្មភាព របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។
- ផ្អែកតាមការកំណត់របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា ស្តីអំពីនយោបាយក្នុង និងក្រៅប្រទេស ។

## សំរេច

<u>មាត្រា ១</u> : - បង្កើតអង្គការរដ្ឋាករគយកម្ពុជាស្ថិតនៅក្នុងក្រសួងពាណិជ្ជកម្មក្នុង និងក្រៅប្រទេស ។ អង្គការរដ្ឋាករគយធានារ៉ាប់រងអនុវត្តត្រឹមត្រូវនយោបាយ ពាណិជ្ជកម្មក្រៅប្រទេស នយោបាយផ្លាស់ប្តូររូបិយវត្ថុ រួមវិភាគបំរើនយោបាយការបរទេស ការពារសន្តិសុខរួម និង ការពារទ្រព្យសម្បត្តិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។

<u>មាត្រា ២</u> : - អង្គការរដ្ឋាករគយ ជាអង្គការមុខងារជំនាញពាក់កណ្តាលប្រដាប់អាវុធ អង្គការគយមានសញ្ញាសំគាល់ និង សំលៀកបំពាក់ ឯកភាព ក្នុងពេលបំពេញមុខងារសញ្ញាសំគាល់របស់អង្គការរដ្ឋាករគយមានរូបសញ្ញាជាតិ និង អក្សរ គយ សរសេរកាត់នៅចំកណ្តាល ។

<u>មាត្រា ៣</u> : - អង្គការគយ មានភារកិច្ច :

+ ត្រួតពិនិត្យទំនិញទូទៅ របស់របរអ្នកដំណើរ រូបិយវត្ថុ លោហធាតុ និងថ្ម ដែលមានតម្លៃពេជ្រ សំបុត្រកញ្ចប់ ឬហិប ដែលផ្ញើតាមប្រៃសណីយ៍ និង មធ្យោបាយដឹកជញ្ជូនក្នុងពេលនាំចេញ_ចូលប្រទេស ។

+ អនុវត្តនយោបាយពន្ធនីហរណ៍_អាហរណ៍ និង អាចទទួលពន្ធផ្សេងៗទៀត ដែលត្រូវប្រគល់ភារៈ ។

+ ពិនិត្យឆែកឆេរ ដើម្បីបង្ការបណ្តាអំពើដែលល្មើស និង ច្បាប់គយ រាល់អំពើលក់ដូរ ផ្ទុកទុកដឹកនាំទំនិញចេញ_ចូលខុសច្បាប់ រាល់ទំនិញដែលត្រូវហាមឃាត់រួមទាំងថ្នាំពុល និង អាវុធ ។

+ រកឃើញដើម្បីបង្ការរាល់អំពើដែលធ្វើឱ្យខូច ឬ នាំឱ្យចូលខាតទំនិញចេញ_ចូលប្រទេស ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយដែលស្ថិតនៅក្រោមកិច្ចត្រួតពិនិត្យរបស់អង្គការរដ្ឋាករគយ ។

មាត្រា ៤ : _ អង្គការរដ្ឋាករគយ មានសិទ្ធិ :

ក_ ឆែកឆេរទំនិញគ្រប់មធ្យោបាយដឹកជញ្ជូន ដែលចត ឬ កំពុងធ្វើចរាចរ និង ឃ្លាំងផ្ទុកទំនិញនាំចេញ_ចូលប្រទេស ។ អ្នកបើកបរគ្រឿងសំភារៈដឹកជញ្ជូន ក៏ដូចជាអ្នកថែរក្សាឃ្លាំង ត្រូវគោរពបញ្ជារបស់បុគ្គលិកគយ ត្រូវបើកទ្វារ បន្ទប់នាវា ហិបទំនិញ រួមទាំងម៉ាស៊ីន តាមសេចក្តីត្រូវការឆែកឆេររបស់អង្គការគយ ។ ឆែកឆេរបញ្ចប់ ឬ ហិបដែលផ្ញើតាមប្រៃសណីយ៍ និង ឯកសារទាំងឡាយដែលផ្ញើមក ឬ ផ្ញើទៅបរទេស ។

ចូលបណ្តាមន្ទីរប្រៃសណីយ៍អន្តរជាតិ ដើម្បីរួមជាមួយបុគ្គលិកប្រៃសណីយ៍ រិះរកកញ្ចប់ ហិបទំនិញ ឬ ឯកសារផ្ញើទៅមក ពីបរទេស ដែលមាន ឬសង្ស័យមានវត្ថុដែលបានហាមឃាត់នាំចេញ_ចូលប្រទេស ។

ឆែកផ្ទះ ឆែកមនុស្សដើម្បីរិះរកទំនិញដែលបានហាមឃាត់ទំនិញរត់ពន្ធ ។ ការឆែកផ្ទះ ឆែកមនុស្ស ត្រូវអនុវត្តត្រឹមត្រូវតាមច្បាប់របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជាបានកំណត់ ។

ខ_ ចាប់ឃាត់បណ្តោះអាសន្ន ទំនិញរបស់របរអ្នកដំណើរ គ្រឿងសំភារៈដឹកជញ្ជូនខុសច្បាប់ ប្រដាប់សំរាប់លាក់ទំនិញខុសច្បាប់ ។ ក្នុងករណីអ្នកល្មើសច្បាប់ដែលមានភស្តុតាង អង្គការគយអាចឃាត់ទុកអ្នកល្មើសច្បាប់នៅនឹងមន្ទីររបស់ខ្លួន ដើម្បីបន្តការស៊ើបអង្កេត ។

គ_ ការវិនិច្ឆ័យរាល់កិច្ចការទាំងឡាយ ដែលល្មើសច្បាប់គយស្ថិតក្រោមកិច្ចដឹកនាំរបស់រដ្ឋអំណាចមូលដ្ឋាន ។ ក្នុងការចាំបាច់ អង្គការគយអាចស្នើប្តឹងទៅមុខតុលាការ ។

ឃ_ ក្នុងពេលបំពេញភារកិច្ច បុគ្គលិកគយបានប្រើប្រាស់អាវុធ ដើម្បីការពារខ្លួន ឬ ដើម្បីបង្ការអំពើប្រឆាំង មិនព្រមគោរពតាមបញ្ជា របស់អង្គការគយ ។

មាត្រា ៥ : _ នៅតាមច្រកព្រំប្រទល់ដែលបើកឱ្យចូលជាអន្តរជាតិ : កំពង់ផែ , ស្ថានីយ៍រថភ្លើង , ចំណតរថយន្ត , មន្ទីរប្រៃសណីយ៍អន្តរជាតិ មានចាត់តាំងអង្គការគយ ។ រាល់ក្រសួងដែលនៅជិតខាងមានភារកិច្ចធ្វើសហការ និង ជួយមធ្យោបាយឱ្យអង្គការគយ ។ នៅតាមទីកន្លែង ដែលពុំទាន់មានការចាត់តាំងអង្គការគយ បណ្តាកងកម្លាំងប្រដាប់អាវុធមានភារកិច្ចបង្ការ និងប្រឆាំងរាល់អំពើល្មើសច្បាប់របស់អង្គការគយ ។

※ រាល់អង្គភាពប្រដាប់អាវុធមានភារកិច្ចជួយអង្គការ និង បុគ្គលិកគយបំពេញភារកិច្ចក្នុងកិច្ចការពិសេសដែលត្រូវការកងកម្លាំងប្រដាប់អាវុធ ។

<u>មាត្រា ៦</u> : - អង្គការគយមានប្រធាន ក្រសួងម្នាក់ទទួលភារៈ និង អនុប្រធានមួយចំនួនជួយធ្វើការ ។ ក្របខ័ណ្ឌរបស់អង្គការគយ ដោយប្រធានក្រសួងគយស្នើ ហើយក្រសួងពាណិជ្ជកម្មក្នុង និង ក្រៅប្រទេសសំរេច ។

ប្រធានក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា
ហេង សំរិន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ធ្វើនៅថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៧៩
*មន្ទីររដ្ឋ*
ស.ម អ៊ុន ផន

# II - ក្រុមប្រឹក្សារដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៦ អ.ន.ក្រ

ស្តីពី ការផ្ទេរទីចាត់ការគយពីក្រសួងពាណិជ្ជកម្ម
អោយទៅក្រសួងហិរញ្ញវត្ថុ

### ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញក្រឹត្យ - ច្បាប់លេខ ០៧ ក្រ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ចនិងនីតិវិធីនៃការធ្វើច្បាប់ និងបទបញ្ជា

— តាមសំណើរបស់ក្រសួងហិរញ្ញវត្ថុ

## សំរេច

មាត្រា១: .— ផ្ទេរទីចាត់ការគយដែលបច្ចុប្បន្នចំណុះក្រសួងពាណិជ្ជកម្ម អោយស្ថិតក្រោមការដឹកនាំនិងគ្រប់គ្រងផ្ទាល់របស់ក្រសួងហិរញ្ញវត្ថុ ។

មាត្រា ២: .— ក្រសួងពាណិជ្ជកម្ម មានភារកិច្ចប្រគល់ទីចាត់ការគយ និង គ្រប់ខ័ណ្ឌកម្មាភិបាល បុគ្គលិក កម្មករ ព្រមទាំងទ្រព្យសម្បត្តិសម្ភារៈផ្សេងៗ ទាំងអស់របស់ទីចាត់ការគយ អោយទៅក្រសួងហិរញ្ញវត្ថុ ។

មាត្រា ៣ .— ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងផែនការ និងបណ្ដាស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៨៨*

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

ប្រធាន

ហត្ថលេខា និង ត្រា

ហ៊ុន សែន

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ៩២០ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០០៣

## ប្រកាស
### ស្តីពី
### ការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយ និងរដ្ឋាករ

~~~~~~

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០១នស ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ០៤អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

### សម្រេច

<u>ប្រការ ១</u> : ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពទីចាត់ការគយ និងរដ្ឋាករ និងមុខងារ និងភារកិច្ច របស់ទីចាត់ការគយ និងរដ្ឋាករ ព្រមទាំងបណ្តាសាខា ការិយាល័យ ទីស្នាក់ការគយនិងរដ្ឋាករ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
N°92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax 855-23-427 798
~~~~~~

**ប្រការ ២** : ទីចាត់ការគយនិងរដ្ឋាករមានមុខងារ និងភារកិច្ច ជាស្ថាប័នមួយស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងការប្រមូលពន្ធលើទំនិញនាំចេញ និងនាំចូល ព្រមទាំងមានភារកិច្ចធ្វើជាសេនាធិការឱ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការងារដូចមានចែងក្នុងជំពូកទី៧ នៃអនុក្រឹត្យដូចយោងខាងលើ ។

**ប្រការ ៣** : ទីចាត់ការគយ និងរដ្ឋាករមានប្រព័ន្ធគ្រប់គ្រងឯកភាពទូទាំងប្រទេសមានសិទ្ធិដឹកនាំបញ្ជា និងត្រួតពិនិត្យលើរាល់អង្គភាពគយនិងរដ្ឋាករ តាំងពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន ខេត្ត ក្រុង តាមការកំណត់របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទីចាត់ការគយ និងរដ្ឋាករដឹកនាំដោយនាយកមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួន មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ជាជំនួយការ ហើយមានរចនាសម្ព័ន្ធដឹកនាំគ្រប់គ្រងដូចខាងក្រោម ៖

១. <u>ថ្នាក់កណ្តាល</u> : មាន ១៦ ការិយាល័យ ចែកជាពីរប្រភេទ ៖

<u>ប្រភេទទី១ : **ការិយាល័យសេនាធិការផ្ទាល់មាន ១០ ការិយាល័យដូចខាងក្រោម ៖**</u>

- ការិយាល័យ រដ្ឋបាល បុគ្គលិក
- ការិយាល័យ វិវាទ និងច្បាប់
- ក្រុមលេខាធិការប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ ដែលចាប់ពីពេលនេះតទៅដូរឈ្មោះទៅជា ការិយាល័យលេខាធិការនិងជំនួយការ
- ការិយាល័យ ត្រួតពិនិត្យ
- ការិយាល័យ តម្លៃ ស្ថិតិ និងឯកសារ ដែលពីពេលនេះតទៅដូរឈ្មោះទៅជា ការិយាល័យបច្ចេកទេសគយ
- ការិយាល័យ គណនេយ្យ
- ការិយាល័យ ស្ថិតិ និង ប្រព័ន្ធព័ត៌មាន
- ការិយាល័យ សវនកម្ម
- ការិយាល័យ កិច្ចការអន្តរជាតិ
- ការិយាល័យ ស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ

<u>ប្រភេទទី២ : **ការិយាល័យបំពេញបែបបទគយមាន ០៦ ការិយាល័យដូចតទៅ**</u> :

- ការិយាល័យ រដ្ឋាករ
- ការិយាល័យគយនិងរដ្ឋាករ ផែស្ងួត
- ការិយាល័យគយនិងរដ្ឋាករ នាំចេញ
- ការិយាល័យគយនិងរដ្ឋាករ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- ការិយាល័យគយនិងរដ្ឋាករ កំពង់ផែភ្នំពេញ
- ការិយាល័យគយនិងរដ្ឋាករ ប្រៃសណីយ៍

២ **អង្គភាពមូលដ្ឋាន ខេត្ត ក្រុង** : មានសាខាគយ និងរដ្ឋាករ ខេត្ត ក្រុងមួយចំនួនដូចតទៅ ៖

- សាខាគយនិងរដ្ឋាករ ខេត្ត កោះកុង
- សាខាគយនិងរដ្ឋាករ ក្រុងព្រះសីហនុ
- សាខាគយនិងរដ្ឋាករ ខេត្ត កំពត
- សាខាគយនិងរដ្ឋាករ ខេត្ត តាកែវ
- សាខាគយនិងរដ្ឋាករ ខេត្ត កណ្តាល
- សាខាគយនិងរដ្ឋាករ ខេត្ត ព្រៃវែង
- សាខាគយនិងរដ្ឋាករ ខេត្ត ស្វាយរៀង
- សាខាគយនិងរដ្ឋាករ ខេត្ត កំពង់ចាម
- សាខាគយនិងរដ្ឋាករ ខេត្ត ស្ទឹងត្រែង
- សាខាគយនិងរដ្ឋាករ ខេត្ត បន្ទាយមានជ័យ
- សាខាគយនិងរដ្ឋាករ ខេត្ត សៀមរាប
- សាខាគយនិងរដ្ឋាករ ខេត្ត បាត់ដំបង
- សាខាគយនិងរដ្ឋាករ ខេត្ត ពោធិសាត់
- សាខាគយនិងរដ្ឋាករ រាជធានីភ្នំពេញ

**ប្រការ ៤** : ការិយាល័យ និងសាខាគយ និងរដ្ឋាករ របស់អង្គភាពទីចាត់ការគយ និងរដ្ឋាករ ដឹកនាំដោយប្រធានមួយរូបមានឋានៈស្មើនឹងប្រធានការិយាល័យគយនិងរដ្ឋាករ និងអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើនិងអនុប្រធានការិយាល័យគយនិងរដ្ឋាករ ដែលទទួលខុសត្រូវតាមភារកិច្ចដែលទីចាត់ការគយនិងរដ្ឋាករបានកំណត់ ។ ផ្អែកទៅតាមការចាំបាច់ ការិយាល័យ ឬសាខាគយនិងរដ្ឋាករខ្លះអាចតំរូវឱ្យមានជំនួយការមួយចំនួនដែលមានឋានៈស្មើនឹងអនុប្រធានស្នាក់ការគយនិងរដ្ឋាករដើម្បីជាជំនួយការបន្ថែមឱ្យប្រធានការិយាល័យឬសាខានោះ ។

**ប្រការ ៥** : ការិយាល័យបុគ្គលិក និងរដ្ឋបាល មានមុខងារនិងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយនិងរដ្ឋាករ លើការងារគ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាករ ទូទាំងព្រះរាជាណាចក្រកម្ពុជាដោយសំរបសំរួលការងារជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ពន្ធ័ក្នុងករណីចាំបាច់ ដោយអនុវត្តរាល់លិខិតបទដ្ឋានរដ្ឋបាលនានាសំរាប់ការគ្រប់គ្រងអាជីព ជាពិសេសការងារ ៖

- រៀបចំ និងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយ និងរដ្ឋាករ ។
- រៀបចំគ្រប់គ្រងស្ថិតិលើទិន្នន័យ បុគ្គលិក និង តារាងពត៏មានសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយនិងរដ្ឋាករ ។
- រៀបចំការងារផ្លាស់ប្តូរ ផ្ទេរភារកិច្ច តម្លើងឋានៈ ឬ បន្ថយឋានៈ ចំពោះមន្ត្រីរាជការគយនិងរដ្ឋាករ ក្រោមឱវាទ ទីចាត់ការគយនិងរដ្ឋាករ ។
- រៀបចំបៀវត្សរ៍ ក្របខ័ណ្ឌ ប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារនិងគ្រប់គ្រងគោលនយោបាយធានារ៉ាប់រងសង្គម និងរបបសំរាកលំហែ ។

- គ្រប់គ្រងការចេញលិខិតឧទ្ទេសនាមឬលិខិតបញ្ជាបេសកកម្មរបស់មន្ត្រីរាជការគយ។
- រៀបចំគោលនយោបាយ លើកសរសើរ ផ្ដល់កិត្តិយស ដាក់វិន័យ ស្ដីបន្ទោស ឬព្រមានដល់មន្ត្រីគយ និងរដ្ឋាករ ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាននានា។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ទីចាត់ការគយនិងរដ្ឋាករ ។
- សរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់ទីចាត់ការគយនិងរដ្ឋាករ ។
- ចាត់ចែង និងសហការរៀបចំទិវាបុណ្យជាតិ និងអន្តរជាតិនានា និងពិធីចាំបាច់ផ្សេងៗក្នុងអង្គភាពគយ និងរដ្ឋាករ ។
- គ្រប់គ្រងស្ថិតិ ការប្រើប្រាស់អាវុធរបស់អង្គភាព ។
- ចាត់ចែងរៀបចំ និងត្រួតពិនិត្យនូវការគោរពវិន័យការងារ ការថែរក្សាសណ្ដាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពក្នុងអង្គភាពគយ និងរដ្ឋាករ ទាំងមូល ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

ប្រការ ៦ : ការិយាល័យវិវាទ និងច្បាប់មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- ទទួលនូវកំណត់ហេតុល្មើសច្បាប់គយ ហើយសិក្សាស៊ើបសួរលដោះស្រាយវិវាទនេះ និងផ្ដល់យោបល់សំរាប់បំរើឱ្យការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានាដាក់ជូននាយកទីចាត់ការគយ និងរដ្ឋាករពិនិត្យ និងសំរេច ។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ស្រាវជ្រាវ ចងក្រងសេចក្ដីព្រាង ក្រម ច្បាប់ បទបញ្ញត្តិវិធាន និងបទដ្ឋាននានាដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ ។
- តម្កល់ឯកសារ និងបទបញ្ញត្តិច្បាប់ជាធរមាននានា និងណែនាំដល់គ្រប់អង្គភាពក្រោមឱវាទទីចាត់ការគយ និងរដ្ឋាករអំពីរបៀបគ្រប់គ្រង ថែទាំឯកសារ ។
- ទទួលពិនិត្យនិងវាយតំលៃដើម្បីសុំការសំរេចពីនាយកទីចាត់ការគយនិងរដ្ឋាករនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជនរួមទាំងអាជីវករ ពាណិជ្ជករ វិនិយោគិននានាក្នុងនាមអង្គភាពទំនាក់ទំនងមហាជនរបស់ទីចាត់ការគយនិងរដ្ឋាករ ក្នុងគោលដៅពង្រឹងការអនុវត្តន៍រាល់បទបញ្ញត្តិច្បាប់ជាធរមាន ក៏ដូចជាជំរុញ និងសំរួលជាអតិបរមាដល់ពាណិជ្ជកម្មអន្តរជាតិ ជាពិសេសជួយដោះស្រាយ និងកាត់បន្ថយនូវភាពអសកម្មនានាដែលបង្កជាឧបសគ្គនាំឱ្យមានការយឺតយ៉ាវ ឬរាំងស្ទះដល់ការបំពេញបែបបទបញ្ចេញទំនិញពីគយ គ្រប់ប្រភេទ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

ប្រការ ៧ : ការិយាល័យលេខាធិការនិងជំនួយការស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ ពីនាយកទីចាត់ការគយនិងរដ្ឋាករ មានមុខងារនិងភារកិច្ចធ្វើជាសេនាធិការឱ្យនាយកទីចាត់ការគយនិងរដ្ឋាករលើការងារ ៖

- ស្រាវជ្រាវ ពិនិត្យ សិក្សា ធ្វើរបាយការណ៍ និងជូនយោបល់ជាប្រចាំលើរាល់ការងារចាំបាច់នានាជូននាយកទីចាត់ការគយនិងរដ្ឋាករ ។

- រៀបចំ តាក់តែង ចងក្រង ថែរក្សានូវបណ្តាឯកសារនានាតាមការចាំបាច់របស់នាយកទីចាត់ការគយនិងរដ្ឋាករ ។
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើទំរង់ចំពោះបណ្តាឯកសារ សេចក្តីព្រាង សំណើលិខិតអនុញ្ញាត ឬកំណត់បង្ហាញមតិនានា មុននឹងបញ្ជូនទៅសុំការសំរេចទីថ្នាក់ដឹកនាំទីចាត់ការគយនិងរដ្ឋាករ ។ ការត្រួតពិនិត្យលើខ្លឹមសារលើឯកសារដូចរៀបរាប់ខាងលើ ធ្វើឡើងតែក្នុងករណីសង្ស័យ ឬយល់ថាចាំបាច់របស់ការិយាល័យ ឬតាមការណែនាំផ្ទាល់របស់ថ្នាក់ដឹកនាំទីចាត់ការគយនិងរដ្ឋាករ ។
- បំពេញបេសកកម្មផ្សេងទៀតតាមការកំណត់ជាក់ស្តែងរបស់នាយកទីចាត់ការគយនិងរដ្ឋាករ ។

ប្រការ ៨ : ការិយាល័យត្រួតពិនិត្យ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតនាំចេញ នាំចូលទំនិញគ្រប់ប្រភេទតាមរបបគយអនុគ្រោះនានាតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ ។
- តាមដានត្រួតពិនិត្យការប្រើប្រាស់សំភារៈបរិក្ខារ និង ទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់ ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬ ជាលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋាន ឬ ពាណិជ្ជកម្មដ្ឋាននានា ស្របតាមនីតិវិធីច្បាប់ជាធរមាន ។
- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រង សកម្មភាពវិនិយោគឯកជនក្នុងក្របខ័ណ្ឌច្បាប់វិនិយោគព្រមទាំងសកម្មភាពនាំចេញ នាំចូលទំនិញរបស់ អង្គការ ស្ថានទូត ស្ថាប័ន ក្រសួង មន្ទីរនានានិងបុគ្គលផ្សេងៗទៀតតាមរបបពិសេសឬអនុគ្រោះនានា។
- ប្រមូលទិន្នន័យ ស្តីពីទំនិញនាំចេញ នាំចូលតាមរបបគយមួយចំនួនតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ ។
- ត្រួតពិនិត្យជាក្រោយលើប្រតិវេទន៍គយ និងឯកសារភ្ជាប់ដែលបណ្តាទីស្នាក់ការគយនិងរដ្ឋាករបានអនុវត្ត និងផ្ញើមកទីចាត់ការគយនិងរដ្ឋាករ ហើយសរុបលទ្ធផល និងលើកឡើងនូវវិធានការចាំបាច់នានា ជូននាយកទីចាត់ការគយ និងរដ្ឋាករពិនិត្យ និងសំរេច ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

ប្រការ ៩ : ការិយាល័យបច្ចេកទេសគយ ពីមុនជាការិយាល័យតម្លៃ ស្ថិតិ និងឯកសារ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- គ្រប់គ្រង កសាង និងតាមដានពិនិត្យការអនុវត្តន៍បទបញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងតារាងពន្ធគយ. ការកំណត់តម្លៃគិតពន្ធ ឬ អាករគយលើទំនិញនាំចេញ នាំចូល

ការវិវត្តន៍នៃការកំណត់ដើមកំណើតទំនិញឱ្យបានទាន់ពេលវេលា និងស្របតាមការវិវត្តន៍នៃសេដ្ឋកិច្ចជាតិនិងពាណិជ្ជកម្មអន្តរជាតិ ។

- ស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីយោងតម្លៃគិតពន្ធ ឬ អាករគយលើទំនិញនាំចេញ នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់តាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិជាធរមាន ព្រមទាំងត្រួតពិនិត្យ ផ្ទៀងផ្ទាត់មើលការអនុវត្តន៍នូវបណ្តាតារាង និងបញ្ជីទាំងនេះ ។
- ប្រមូលផ្តុំទិន្នន័យ ទំនិញនាំចេញ នាំចូល ដែលពន្ធ ឬ អាករពុំមែនជាបន្ទុករបស់រដ្ឋជាលក្ខណៈសង្ខេបជាប្រចាំរាល់ដំណាច់ខែ ត្រីមាស ឆ្នាំនិមួយៗ ។
- បំពេញតួនាទី ពិនិត្យ និងផ្តល់យោបល់លើការកំណត់តម្លៃគិតពន្ធគយ ឬ អាករគយលើវិក័យប័ត្រនានាតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

<u>ប្រការ ១០</u> : ការិយាល័យ គណនេយ្យ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយនិងរដ្ឋាករលើការងារ ៖

- លើកគំរោងផែនការប្រមូលចំណូលពន្ធ អាករគ្រប់ប្រភេទ របស់ទីចាត់ការគយ និងរដ្ឋាករ និងតាមដានរំលឹកអំពីការប្រតិបត្តិ ។
- ប្រមូលផ្តុំនិងសំរបសំរួលជំពូកថវិកា នីតិវិធីនានា បំរើឱ្យការងារគណនេយ្យពន្ធគយ។
- គ្រប់គ្រងប្រាក់ពន្ធលើទំនិញនាំចេញ នាំចូល ប្រាក់ផាកពិន័យ ប្រាក់រង្វាន់ ប្រាក់បំណុល ប្រាក់បៀវត្សរ៍ និងរាល់ចំណូលផ្សេងៗទៀតដែលមាន ។
- ប្រមូលផ្តុំគំរូការ និងធ្វើកម្មវិធីចំណាយរបស់អង្គភាព ។
- គ្រប់គ្រងបែងចែកមធ្យោបាយសំភារៈ បរិក្ខានានាសំរាប់បំរើការងាររបស់អង្គភាព ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សំភារៈ ធ្វើបញ្ជីសារពើភណ្ឌ និងគ្រប់គ្រងការប្រើប្រាស់អាគារ ការរៀបចំជួសជុលផ្សេងៗរបស់អង្គភាព ។
- តាមដាន រំលឹក ការគ្រប់គ្រងគណនីពិសេស។
- កាន់កាប់រាល់សាលាកប័ត្រ និងបញ្ជីគណនេយ្យរបស់ទីចាត់ការគយនិងរដ្ឋាករ ។
- ដោះពុម្ពបង្កាន់ដៃពន្ធ ឯកសារបច្ចេកទេសបញ្ជីគណនេយ្យ ឯកសាររដ្ឋបាល តែមប្រិ និងឯកសារនានាដែលទាក់ទងនឹងការងារប្រមូលពន្ធរបស់អង្គភាព ។
- លើកគំរោងចំណាយថវិកាប្រចាំឆ្នាំ ធ្វើរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ និងធ្វើរបាយការណ៍សំរេចទូទាត់ចំណូល ចំណាយថវិកាប្រចាំឆ្នាំ របស់ទីចាត់ការគយនិងរដ្ឋាករ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

<u>ប្រការ ១១</u> : ការិយាល័យសវនកម្មមានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តន៍នូវរាល់បណ្តាវិធាន បទបញ្ញត្តិ និងបទដ្ឋាននានា ពាក់ពន្ធ័នឹងសមត្ថកិច្ច កាតព្វកិច្ច និងអភិបាលកិច្ចរបស់រដ្ឋបាលគយ និងរដ្ឋាករ ។
- ធ្វើសវនកម្មលើសកម្មភាពប្រតិបត្តិរបស់អង្គភាពនានាក្រោមឱវាទ ទីចាត់ការគយនិងរដ្ឋាករ តាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។
- សិក្សា និងវិភាគបញ្ហានានាពាក់ពន្ធ័នឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទិសដៅកែលំអការងារនេះ ។
- ពង្រឹងតំលាភាព និងប្រសិទ្ធភាពក្នុងការប្រមូលពន្ធ និងអាករជូនរដ្ឋ។
- លើកឡើងនូវផែនការសមស្របសំរាប់កែលំអជាប្រចាំ នូវការគ្រប់គ្រងហិរញ្ញវត្ថុ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

**ប្រការ ១២ :** ការិយាល័យកិច្ចការអន្តរជាតិមានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- លើកឡើងនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យគយនិងរដ្ឋាករកម្ពុជាក្នុងបរិបទសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក ។
- សិក្សា និងផ្តល់អនុសាសន៍ ស្តីពីការចូលរួមប្រតិបត្តិការផ្នែកគយ នៅក្នុងអង្គការតំបន់ និងពិភពលោក ព្រមទាំងជំរុញបង្កើនទំនាក់ទំនងទ្វេភាគី ជាមួយរដ្ឋបាលគយ នៃប្រទេសផ្សេងៗ ។
- តាមដាន និងសំរបសំរួលការអនុវត្តន៍នូវរាល់កាតព្វកិច្ចរបស់កម្ពុជាពាក់ ពន្ធ័នឹងកិច្ចការគយ ក្រោមកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី ។
- វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍អំពីផលប៉ះពាល់ផ្សេងៗដែលអាចកើតមានឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីទាំងនោះ ជាពិសេសពាក់ពន្ធ័នឹងចំណូលពន្ធគយ ។
- សំរបសំរួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

**ប្រការ ១៣ :** ការិយាល័យស្ថិតិនិងប្រព័ន្ធព័ត៌មាន មានមុខងារនិងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយនិងរដ្ឋាករលើការងារ ៖

- លើកឡើងនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជាក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងរដ្ឋបាលគយ និងរដ្ឋាករ ។
- រៀបចំគ្រប់គ្រងការស្រង់ ប្រមូល និងរក្សាទិន្នន័យ ស្ថិតិ នៃការនាំចេញ នាំចូល ។
- រៀបចំតភ្ជាប់បណ្តាញកុំព្យូទ័រនៅក្នុងរដ្ឋបាលគយនិងរដ្ឋាករកម្ពុជា ព្រមទាំងគ្រប់គ្រងការប្រើប្រាស់ និងថែរក្សាបណ្តាញនេះ ។

- សំរបសំរួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសំរាប់បំរើពាណិជ្ជកម្មអន្តរជាតិ ។
- ប្រមូលផ្តុំពត៌មាន និងផ្សព្វផ្សាយពត៌មាន ពាក់ពន្ធ័នឹងកិច្ចការគយនិងរដ្ឋាករដល់អាជីវករ និងអតិថិជនដោយប្រើប្រាស់គ្រប់មធ្យោបាយរួមទាំងមធ្យោបាយអេឡិចត្រូនិកផង។
- សហការជាមួយអង្គការតំបន់ និងអន្តរជាតិ ព្រមទាំងរដ្ឋបាលគយ នៃប្រទេសផ្សេងទៀតក្នុងការផ្លាស់ប្តូរពត៌មាន ការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

__ប្រការ ១៤__ : ការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- ចាត់វិធានការស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ និងគេចពន្ធគ្រប់ប្រភេទ លើទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ចាត់តាំងបណ្តាញសម្ងាត់ កំលាំងពិសេស ទប់ស្កាត់បង្ក្រាបរាល់ អំពើល្មើសច្បាប់គយ អំពើរត់ពន្ធគយផ្សេងទៀតទប់ស្កាត់រាល់អំពើវិទ្ធង្សនាសេដ្ឋកិច្ចជាតិ ។
- ធ្វើកំណត់ហេតុកត់ត្រា កំណត់ហេតុចាប់ឃាត់ រាល់ពេលដែលយល់ថាចាំបាច់ក្នុងពេលប្រតិបត្តិការម្តងៗ ។
- រក្សាទុកទំនិញដែលឃាត់ទុកបណ្តោះអាសន្នរង់ចាំការសំរេចវិនិច្ឆ័យជាស្ថាពរពីអង្គការមានសមត្ថកិច្ចនានា ។
- ចាត់តាំងក្រុមប្រតិបត្តិការស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ ធ្វើសកម្មភាពតាមគោលដៅសំខាន់ៗចាំបាច់នៅទូទាំងប្រទេសតាមបទបញ្ជារបស់ នាយកទីចាត់ការគយ និងរដ្ឋាករ ។
- ប្រមូលរាល់ពត៌មានសំខាន់ៗ ជាពិសេសពាក់ពន្ធ័នឹងមុខទំនិញ បុគ្គល មធ្យោបាយដឹកជញ្ជូន និងល្បិចល្មើសគ្រប់ប្រភេទជារៀងរាល់ខែ ពីគ្រប់បណ្តាសាខា ការិយាល័យស្នាក់ការគយនិងរដ្ឋាករនានា ហើយសំយោគជាឯកសារសម្ងាត់រួមមួយបំរើឱ្យការងារបង្ក្រាបអំពើរត់ពន្ធរបស់សមត្ថកិច្ចលើផ្ទៃប្រទេស ក៏ដូចជាសមត្ថកិច្ចដែនដី ។
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់នាយកទីចាត់ការគយនិងរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

__ប្រការ ១៥__ : ការិយាល័យរដ្ឋាករ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករ លើការងារ ៖

- ចាត់ចែងត្រួតពិនិត្យ និងប្រមូលពន្ធ និងអាករ លើការនាំចូលផលិតផលគេលសិលាតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ។
- គ្រប់គ្រងការបំពេញបែបបទនាំចូល ចរាចរសន្និធិផលិតផលគេលសិលា នៅទូទាំងប្រទេសគិតទាំងមណ្ឌលឃ្លាំងឬអាជីវកម្មដ្ឋាននានាតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន។

- ចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ស្រាវជ្រាវ និងបង្ក្រាបអំពើបទល្មើសគយលើផលិតផលគេលសិលា ។
- គ្រប់គ្រងហាងលក់ទំនិញរួចពន្ធនៅទូទាំងប្រទេស ។
- គ្រប់គ្រងតែមប្រើគយ និងរដ្ឋាករ និងទទួលកិច្ចការក្នុងវិស័យរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

<u>ប្រការ ១៦</u> : ការិយាល័យគយ និងរដ្ឋាករផែស្ងួត មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយនិងរដ្ឋាករលើការងារ ៖

- ចាត់ចែងការគ្រប់គ្រងទៅលើរាល់ទីស្នាក់ការគយ និងរដ្ឋាករផែស្ងួតក្រោមឱវាទ តាមប្រកាសលេខ ១២១៤ សហវ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ១៩៩៩ ។
- អនុវត្តគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មក្រៅប្រទេសដោយអនុវត្តច្បាប់ និងបទបញ្ញានានា ពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញ នាំចូល តាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ។
- ប្រមូលទិន្នន័យលើទំនិញនាំចេញ នាំចូលតាមរបបគយនីមួយៗ លើរាល់ទំនិញដែលនាំចូល ឬ នាំចេញតាមស្នាក់ការផែស្ងួត ក្រោមឱវាទនីមួយៗ ។
- ចាត់វិធានការស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធគយ ក្នុងបណ្តុំមូលដ្ឋានផែស្ងួតនានា ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

<u>ប្រការ ១៧</u> : ការិយាល័យគយនិងរដ្ឋាករនាំចេញមានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយនិងរដ្ឋាករលើការងារ ៖

- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យសំរាប់កិច្ចប្រតិបត្តិការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញ ដែលស្ថិតក្រោមរូបភាពវិនិយោគដែលមានមូលដ្ឋានអាជីវកម្មក្នុងតំបន់ក្រុងភ្នំពេញ ខេត្តកំពង់ស្ពឺ និងខេត្តកណ្តាល ។ ចំពោះមូលដ្ឋានអាជីវកម្មនៅតាមបណ្តាខេត្តក្រុងផ្សេងទៀតអាចធ្វើទៅបានតែតាមសំណើរបស់សាមីក្រុមហ៊ុន និងមានការឯកភាពជាមុនពីនាយកទីចាត់ការគយនិងរដ្ឋាករ ។
- គ្រប់គ្រងត្រួតពិនិត្យប្រមូលពន្ធ និងបញ្ជប់បែបបទគយតាមបញ្ញត្តិច្បាប់រួចជាធរមានលើទំនិញនាំចេញដូចចែងខាងលើ តាមបណ្តាឃ្លាំង និងមូលដ្ឋានអាជីវកម្ម របស់វិនិយោគិនតាមការស្នើសុំអញ្ជើញត្រួតពិនិត្យពីសាមីអាជីវករ វិនិយោគិននីមួយៗ ។
- គ្រប់គ្រងស្ថិតិទំនិញនាំចេញតាមផ្លូវគោក ទឹក អាកាស ដើម្បីរាយការណ៍ជូនទីចាត់ការគយ និងរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។

ប្រការ ១៨ : ការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានមុខងារនិងភារកិច្ច ធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករ លើការងារ ៖

- អនុវត្តគោលនយោបាយដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មក្រៅប្រទេសអនុវត្តច្បាប់ និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងការងារត្រួតពិនិត្យ និងប្រមូលពន្ធ លើទំនិញនាំចេញ នាំចូល ។
- ចាត់ចែងត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងទំនិញនាំចេញ នាំចូលគ្រប់គ្រប់ប្រភេទ រួមទាំងឥវ៉ាន់អ្នកដំណើរ រូបបីយប័ណ្ណ លោហធាតុ ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ ភណ្ឌិការប្រៃសណីយ៍ផ្សេងៗតាមមាត់ច្រកអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ។
- ធ្វើបែបបទយន្តហោះ ចេញ ចូល អាកាសយានដ្ឋានពោធិចិនតុង ។
- ចាត់វិធានការស្រាវជ្រាវ និងទប់ស្កាត់បង្ក្រាបរាល់អំពើរត់ពន្ធគយ រត់ពន្ធគ្រឿងញៀន និងទំនិញហាមឃាត់នានាតាមសមត្ថកិច្ចរបស់ខ្លួន ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយក្រោមឱវាទ ។

ប្រការ ១៩ : ការិយាល័យគយនិងរដ្ឋាករកំពង់ផែភ្នំពេញ មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- អនុវត្តគោលនយោបាយ ដែលពាក់ព័ន្ធនឹងការងារផ្លាស់ប្តូរពាណិជ្ជកម្មក្រៅប្រទេស អនុវត្តច្បាប់ និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញ នាំចូលគ្រប់ប្រភេទ ។
- ចាត់វិធានការស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធគយគ្រប់ប្រភេទនៅក្នុងវង្ងទទួលខុសត្រូវរបស់ខ្លួន ។
- ចាត់ចែងត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងទំនិញនាំចេញ នាំចូលគ្រប់ប្រភេទឥវ៉ាន់អ្នកដំណើរ រូបបីយប័ណ្ណ លោហធាតុ ត្បូងថ្មមានតម្លៃ បេតិកភ័ណ្ឌវប្បធម៌ ភណ្ឌិកាប្រៃសណី ។
- គ្រប់គ្រង និងធ្វើបែបបទនាវាចេញ ចូល ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយ និងរដ្ឋាករក្រោមឱវាទ ។

ប្រការ ២០ : ការិយាល័យគយ និងរដ្ឋាករប្រៃសណីយ៍មានមុខងារ និងភារកិច្ចធ្វើជាសេនាធិការឱ្យទីចាត់ការគយ និងរដ្ឋាករលើការងារ ៖

- ធ្វើបែបបទភណ្ឌិកាប្រៃសណីយ៍ ។
- អនុវត្តច្បាប់ និងបទបញ្ញត្តិនានាពាក់ព័ន្ធនឹងការត្រួតពិនិត្យ និងប្រមូលពន្ធលើទំនិញនាំចេញ និងនាំចូលគ្រប់ប្រភេទ ។

- ចាត់វិធានការស្រាវជ្រាវនិងបង្ក្រាបអំពើរត់ពន្ធគ្រប់ប្រភេទនៅក្នុងវង្វង់ទទួលខុសត្រូវរបស់ខ្លួន ។
- ចាត់ចែងត្រួតពិនិត្យឡើងវិញលើបង្កាន់ដៃពន្ធយានយន្តនានា មុននឹងបញ្ជាក់បែបបទផ្តល់ផ្លាកលេខប្រើប្រាស់ទៅឱ្យអតិថិជន ។
- គ្រប់គ្រងធនធានមនុស្សនិងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយក្រោមឱវាទ ។

<u>ប្រការ ២១</u> : សាខាគយនិងរដ្ឋាករ មានមុខងារ និងភារកិច្ចគ្រប់គ្រងដឹកនាំបញ្ជាដោយផ្ទាល់លើបណ្តាទីស្នាក់ការគយ និងរដ្ឋាករនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ។ ទីស្នាក់ការគយ និងរដ្ឋាករ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើនឹងអនុប្រធានការិយាល័យគយនិងរដ្ឋាករ និងអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើនឹងអនុប្រធានស្នាក់ការគយនិងរដ្ឋាករ ជាអ្នកទទួលខុសត្រូវតាមភារកិច្ចដែលទីចាត់ការគយនិងរដ្ឋាករបានកំណត់ជូន ។

<u>ប្រការ ២២</u> : សាខាគយ និងរដ្ឋាករ ខេត្ត ក្រុង ជាឋានានុក្រមរដ្ឋបាល ថ្នាក់មូលដ្ឋាន របស់ទីចាត់ការគយនិងរដ្ឋាករ មានភារកិច្ច ៖

- គ្រប់គ្រងតាមឋានានុក្រមរដ្ឋបាល និងបច្ចេកទេស រាល់ទីស្នាក់ការគយ និងរដ្ឋាករដែលស្ថិតក្រោមឱវាទរបស់ខ្លួនមកតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ។
- អនុវត្តគោលនយោបាយដែលពាក់ពន្ធ័នឹងការផ្លាស់ប្តូរពាណិជ្ជកម្មក្រៅប្រទេសអនុវត្តច្បាប់ និងបទបញ្ញត្តិនានាពាក់ពន្ធ័នឹងការងារត្រួតពិនិត្យ និងប្រមូលពន្ធ លើទំនិញនាំចេញ នាំចូលគ្រប់ប្រភេទ ។
- ប្រមូលផ្តុំទិន្នន័យទំនិញនាំចេញ នាំចូល ឥវ៉ាន់អ្នកដំណើរ រូបិយប័ណ្ណ លោហធាតុត្បូងថ្មមានតម្លៃ បេតិកភ័ណ្ឌវប្បធម៌ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ។
- ចាត់តាំងកំលាំងចល័តរបស់មូលដ្ឋាននីមួយៗសំរាប់បំរើឱ្យការស្រាវជ្រាវ ទប់ស្កាត់និងបង្ក្រាបអំពើរត់ពន្ធគ្រប់ប្រភេទតាមសមត្ថកិច្ចដែនដីភូមិសាស្ត្រខេត្ត ក្រុងនិមួយៗ ឬតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ដោយសហការយ៉ាងជិតស្និទ្ធជាមួយការិយាល័យស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធ នៃទីចាត់ការគយ និងរដ្ឋាករ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា ជាពិសេសអាជ្ញាធរដែនដី តុលាការមូលដ្ឋាននិមួយៗ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយក្រោមឱវាទ ។

<u>ប្រការ ២៣</u> : ទីស្នាក់ការគយនិងរដ្ឋាករជាឋានុក្រមរដ្ឋបាលថ្នាក់មូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ពីសាខាគយនិងរដ្ឋាករពាក់ព័ន្ធ ហើយមានមុខងារ និងភារកិច្ចដូចខាងក្រោម ៖

- អនុវត្តការប្រមូលពន្ធ និងអាករគ្រប់ប្រភេទតាមការកំណត់នៃច្បាប់ និងបទបញ្ញត្តិនានាលើរាល់ទំនិញនាំចេញ នាំចូល ។

- ស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើសច្បាប់គយ ពិសេសគឺប្រយុទ្ធប្រឆាំងនឹងអំពើរត់ពន្ធគ្រប់ប្រភេទក្នុងដែនគ្រប់គ្រងរបស់ខ្លួន ។
- ធ្វើបែបបទ និងត្រួតពិនិត្យដោយផ្ទាល់លើឯកសារ លើមធ្យោបាយដឹកជញ្ជូន និងលើទំនិញ នាំចេញ នាំចូលគ្រប់ប្រភេទតាមមាត់ច្រករបស់ខ្លួន ផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាន ។
- ប្រមូលទិន្នន័យទំនិញនាំចេញ នាំចូលតាមមាត់ច្រកដែលខ្លួនគ្រប់គ្រង ។
- គ្រប់គ្រង និងកែលំអជាប្រចាំនូវធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយក្រោមឱវាទ ។

<u>ប្រការ ២៤</u> : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយ និងរដ្ឋាករ មានឋានៈស្មើរដ្ឋលេខាធិការ ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៨ / ៩៩ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ១៩៩៨ ត្រូវបំពេញភារកិច្ចក្រោមការដឹកនាំផ្ទាល់របស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសំរបសំរួលការងារជាមួយនឹងអគ្គលេខាធិការក្រសួង សមស្របតាមមាត្រា២៤ នៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ។

<u>ប្រការ ២៥</u> : ការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្នាក់ការគយនិងរដ្ឋាករត្រូវកំណត់ដោយនាយកទីចាត់ការគយនិងរដ្ឋាករ ។ ចំពោះមុខងារ និងភារកិច្ចពាក់ពន្ធ័នឹងការងារគយនិងរដ្ឋាករផ្សេងទៀតដែលពុំបានចែងក្នុងប្រកាសនេះត្រូវពិនិត្យ និងសំរេចប្រគល់មុខងារ និងភារកិច្ចទាំងនេះបន្ថែមទៀតដល់សាខា និងការិយាល័យគយនិងរដ្ឋាករនានាដោយនាយកទីចាត់ការគយនិងរដ្ឋាករ តាមការយល់ថា ចាំបាច់ ។

<u>ប្រការ ២៦</u> : ប្រកាសទាំងឡាយដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ ២៧</u> : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ និងប្រធាននាយកដ្ឋាន អង្គភាពពាក់ពន្ធ័នានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាខាខេត្ត-ក្រុង
  ដើម្បីជូនជ្រាប
- ទីចាត់ការគយនិងរដ្ឋាករ
  ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...០០១... សហវ.......

រាជធានី ភ្នំពេញ,ថ្ងៃទី ១៤ ខែ[illegible]ឆ្នាំ ២០០៤

# សេចក្ដីសំរេច
# ស្ដីពី
# ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ឧត្ដរមានជ័យ

*****

## ទេសរដ្ឋមន្ដ្រី រដ្ឋមន្ដ្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្ដីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១:** ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ឧត្ដរមានជ័យ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត ឧត្ដរមានជ័យ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

សាខាគយ-រដ្ឋាករ ខេត្ត ឧត្ដរមានជ័យ បោះទីតាំងនៅ ទីរួមខេត្ត ឧត្ដរមានជ័យមានភារកិច្ចគ្រប់គ្រងរាល់ ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តឧត្ដរមានជ័យ : ទីស្នាក់ការគយ និងរដ្ឋាករអូរស្មាច់, ទីស្នាក់ការគយនិងរដ្ឋាករជាំ ឬ សង៉ាំ (ស្រុក អន្លង់វែង) និង ទីស្នាក់ការគយនិងរដ្ឋាករ ព្រះប្រឡាយ (ស្រុកត្រពាំងប្រាសាទ) ។ ដោយឡែកសាខាគយនិងរដ្ឋាករនេះក៏មានភារកិច្ចបង្កើតនិងប្រើប្រាស់កម្លាំងចល័ត សហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធនានាក្នុងភូមិសាស្ត្រនៃខេត្ត ឧត្ដរមានជ័យ ទាំងមូល ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល
២- ផ្នែក ត្រួតពិនិត្យ
៣- ផ្នែក គណនេយ្យ
៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ
៥- ផ្នែក បច្ចេកទេសគយ
៦- ផ្នែក វិវាទនិងច្បាប់

__ប្រការ ២__ សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

__ប្រការ ៣__ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

__កន្លែងទទួល :__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត ឧត្តរមានជ័យ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

គាត ឈន់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៣ សហវ

រាជធានី ភ្នំពេញ, ថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០០៤

## សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ
## ខេត្ត កំពង់ធំ

*****

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្ដីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**ប្រការ ១:** ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត កំពង់ធំ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត កំពង់ធំ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

- សាខាគយ-រដ្ឋាករខេត្តកំពង់ធំ បោះទីតាំងនៅទីរួមខេត្ត កំពង់ធំ មានភារកិច្ចគ្រប់គ្រងរាល់ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តកំពង់ធំ : មានភារកិច្ចគ្រប់គ្រងបញ្ជាកម្លាំងចល័តក្នុងខេត្តកំពង់ធំ និង ខេត្តព្រះវិហារ ទប់ស្កាត់ទំនិញល្មើសឆ្លងកាត់ពីខេត្តបន្ទាយមានជ័យនិងសៀមរាប ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax : 855-23-427 798

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល
២- ផ្នែក ត្រួតពិនិត្យ
៣- ផ្នែក គណនេយ្យ
៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ
៥- ផ្នែក បច្ចេកទេសគយ
៦- ផ្នែក វិវាទនិងច្បាប់

**ប្រការ ២** សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

**ប្រការ ៣** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត កំពង់ធំ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

2

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: 003 សហវ

រាជធានី ភ្នំពេញ,ថ្ងៃទី ១៥ ខែ........ឆ្នាំ ២០០៤

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតនិងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ
## ខេត្ត ក្រចេះ
*****
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យ លេខ ០៤/អនក្រ/បក/១៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ លេខ ៦៤/អនក្រ/បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០១
- បានឃើញ ច្បាប់ស្ដីពីពន្ធលើទំនិញ នាំចេញ និងនាំចូល ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦-០៧-១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋ
- យោងចំណារឯកភាព របស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ២០០៣លើលិខិតលេខ ៥៩៨៧ សហវ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១:** ក- បង្កើត និងដាក់ឱ្យដំណើរការ សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ ។

ខ- សាខាគយនិងរដ្ឋាករ ខេត្ត ក្រចេះ មានភារកិច្ច សិទ្ធិ និង ទីតាំងដូចខាងក្រោម ÷

- សាខាគយ-រដ្ឋាករខេត្ត ក្រចេះ បោះទីតាំងនៅទីរួមខេត្ត ក្រចេះ មានភារកិច្ចគ្រប់គ្រងរាល់ទីតាំងគយនិងរដ្ឋាករទាំងអស់ដែលមាននៅក្នុងខេត្តក្រចេះ : ទីស្នាក់ការគយនិងរដ្ឋាករស្នួល , ទីស្នាក់ការគយនិងរដ្ឋាករជ័យឃ្លាំង និង ទីស្នាក់ការគយនិងរដ្ឋាករ ត្រពាំងស្រែ ។ ដោយឡែកសាខាគយនិងរដ្ឋាករនេះក៏មានភារកិច្ចបង្កើតនិងប្រើប្រាស់កម្លាំងចល័ត សហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសគេចពន្ធនានាក្នុងភូមិសាស្ត្រនៃខេត្តក្រចេះទាំងមូល ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone 855-23-724 664 Fax : 855-23-427 798

គ- ក្បាលម៉ាស៊ីនរបស់សាខាគយនិងរដ្ឋាករ ត្រូវបែងចែកជាផ្នែកគឺ ÷

១- ផ្នែក រដ្ឋបាល

២- ផ្នែក ត្រួតពិនិត្យ

៣- ផ្នែក គណនេយ្យ

៤- ផ្នែកប្រឆាំងនិងបង្ក្រាបអំពើរត់ពន្ធ

៥- ផ្នែក បច្ចេកទេសគយ

៦- ផ្នែក វិវាទនិងច្បាប់

<u>ប្រការ ២</u> សាខាគយនិងរដ្ឋាករនេះ មាន ប្រធាន មួយរូបដឹកនាំ និង អនុប្រធានមួយចំនួនជាជំនួយការ ។
ប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង ប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករនិងមានឋានៈស្មើនឹងអនុប្រធាន មន្ទីរនានាជុំវិញខេត្ត ក្រុង ។
អនុប្រធានសាខាគយនិងរដ្ឋាករមានឋានៈស្មើនឹង អនុប្រធានការិយាល័យនៅទីចាត់ការគយនិងរដ្ឋាករ និងមានឋានៈស្មើនឹង ប្រធានការិយាល័យ នៃមន្ទីរនានាជុំវិញខេត្ត ក្រុង ។

<u>ប្រការ ៣</u> ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និង សាខាគយនិងរដ្ឋាករ ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវមានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**<u>កន្លែងទទួល :</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  « ដើម្បីជូនជ្រាប »
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អភិបាលខេត្ត ក្រចេះ
  « ដើម្បីសហការអនុវត្ត »
- ដូចប្រការ ៣ « ដើម្បីអនុវត្ត »
- កាលប្បវត្តិ - ឯកសារ

**គាត ឈន់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...២០២............ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០៥

# ប្រកាស
# ស្តីពី
# ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១១៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ /១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញលិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងលេខ០២បប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ លើលិខិតលេខ ០២៥សហវ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពី វិធានការរយៈពេលខ្លី និងមធ្យម ដើម្បីជំរុញកំណើនចំណូលពន្ធ អាករ ដែលប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ក៏ដូចជាចំណូលសារពើពន្ធ ។
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សំរេច

**ប្រការ ១ :** បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានការិយាល័យកណ្តាលបោះប្រចាំនៅក្រុងប៉ៃលិន ។

**ប្រការ ២ :** សាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន ដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣ :** សាខាគយនិងរដ្ឋាករ ក្រុងប៉ៃលិន មានភារកិច្ចដូចតទៅ ៖

១- គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់លើទីស្នាក់ការគយនិងរដ្ឋាករទាំងអស់ ក្នុងភូមិសាស្ត្រ ក្រុងប៉ៃលិន និងលើអង្គភាពស្រាវជ្រាវ អង្គភាពចល័ត និងត្រៀមអន្តរាគមន៍នានាក្រោមឱវាទ ។

២- ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ពន្ធ័ទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់ នៃទំនិញនាំចូលនិងការទទួលខុសត្រូវចំពោះមុខច្បាប់រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬ ដោយប្រយោលការធ្វើចរាចរចែកចាយសន្និធិទំនិញនាំចូលដោយល្មើសនានាក្នុងមូលដ្ឋាន អាជីវកម្មដ្ឋាន ឬ លំនៅដ្ឋាននិមួយៗ ។

៣- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់ក្រុងប៉ៃលិន លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយ ឬកំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានាដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

៤- ចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិ អាជីវកម្មដ្ឋានលក់ដុំ លក់រាយ ភណ្ឌាគារសន្និធិទំនិញនានា ដែលស្ថិតក្រោមប្រពន្ធ័គ្រប់គ្រងពិសេស រួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលគេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញរសើបមួយចំនួនទៀតដែលនឹងកំណត់ដោយទីចាត់ការគយនិងរដ្ឋាករ ។

៥- អនុវត្តតាមភារកិច្ចផ្សេងៗដែលនឹងកំណត់តាមការចាំបាច់នានា ដោយទីចាត់ការគយនិងរដ្ឋាករស្របតាមបញ្ញត្តិច្បាប់ជាធរមាន ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចប្រចាំមូលដ្ឋាន ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវភារកិច្ចដូចរៀបរាប់ខាងលើ ។

**ប្រការ ៤ :** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>**ប្រការ ៥**</u> : អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ពន្ធ័ផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>**ចម្លងជូន**</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ ( ដើម្បីជូនជ្រាប )
- សាលាក្រុងប៉ៃលិន
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  ( ដើម្បីជូនជ្រាប និងសុំកិច្ចសហការអនុវត្ត )
- ដូចប្រការ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១០៥ សហវ.ពក.

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៥

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ ខេត្តកំពង់ឆ្នាំង

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញលិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងលេខ០២បប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៥ លើលិខិតលេខ ០២៥សហវ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពី វិធានការរយៈពេលខ្លី និងមធ្យម ដើម្បីជំរុញកំណើនចំណូលពន្ធ អាករ ដែលប្រមូលដោយទីចាត់ការគយនិងរដ្ឋាករ ក៏ដូចជាចំណូលសារពើពន្ធ ។
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

## សំរេច

**ប្រការ ១** : បង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយនិងរដ្ឋាករ ខេត្តកំពង់ឆ្នាំង ថ្នាក់ប្រហាក់ប្រហែលមន្ទីរនានាជុំវិញខេត្ត ក្រុង ដែលស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានការិយាល័យកណ្តាលបោះប្រចាំនៅឡើមខេត្តកំពង់ឆ្នាំង ។

**ប្រការ ២** : សាខាគយនិងរដ្ឋាករខេត្តកំពង់ឆ្នាំងដឹកនាំដោយប្រធានសាខាមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣** : សាខាគយនិងរដ្ឋាករ ខេត្តកំពង់ឆ្នាំងមានភារកិច្ចដូចតទៅ ៖

១- គ្រប់គ្រង ដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់ លើអង្គភាពស្រាវជ្រាវ អង្គភាពចល័ត និងត្រៀមអន្តរាគមន៍នានាក្រោមឱវាទ ។

២- ចាត់ចែង រៀបចំ ផ្សព្វផ្សាយតាមរូបភាពនានាដល់អាជីវករ និងបុគ្គលពាក់ពន្ធ័ទាំងឡាយឱ្យយល់ដឹងទាន់ពេលវេលាពីភាពស្របច្បាប់ នៃទំនិញនាំចូលនិងការទទួលខុសត្រូវចំពោះមុខច្បាប់រាល់ពេលរកឃើញមានការចូលរួមគេចវេសកាតព្វកិច្ចពន្ធ អាករដោយផ្ទាល់ ឬ ដោយប្រយោលការធ្វើចរាចរចែកចាយសន្និធិទំនិញនាំចូលដោយល្មើសនានាក្នុងមូលដ្ឋាន អាជីវកម្មដ្ឋាន ឬ លំនៅដ្ឋាននិមួយៗ ។

៣- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគយនានាក្នុងភូមិសាស្ត្រគ្រប់គ្រងរបស់ខេត្តកំពង់ឆ្នាំង លើទំនិញនាំចូលដោយគេចពន្ធតាមគ្រប់រូបភាពដែលកំពុងសន្និធិចរាចរ ចែកចាយឬកំពុងប្រើប្រាស់តាមបណ្តាអាជីវកម្មដ្ឋាន ភណ្ឌាគារទំនិញ មូលដ្ឋានផលិតកម្ម ឬលំនៅដ្ឋាននានាដោយអនុលោមតាមនីតិវិធីច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានតំបន់រួចពន្ធ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់ ។

**ប្រការ ៣.-**

ការិយាល័យគោលនយោបាយ និងគ្រប់គ្រងតំបន់រួចពន្ធ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រងកិច្ចដំណើរការតំបន់រួចពន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសបណ្តាតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ការអនុវត្តល្អបំផុតជាអន្តរជាតិ និងអនុសញ្ញាទីក្រុងក្យូតូស្តីពីការធ្វើឲ្យសាមញ្ញ និងស៊ីចង្វាក់នៃនីតិវិធីគយ សំដៅធានាឲ្យបាននូវភាពរលូន និងទប់ស្កាត់ហានិភ័យ/ទប់រហ័សក្នុងការបំពេញបែបបទលើទំនិញចេញ និងចូលតំបន់ទាំងនេះ
- សម្របសម្រួលឲ្យការបំពេញបែបបទគយនាំចេញ នាំចូល ឬឆ្លងកាត់ទៅមក របស់ទំនិញ និងមធ្យោបាយដឹកជញ្ជូនរបស់តំបន់សេដ្ឋកិច្ចពិសេសអាចប្រព្រឹត្តទៅបានរលូន ស្របតាមនីតិវិធីគយពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស និងបទប្បញ្ញត្តិច្បាប់ផ្សេងទៀតជាធរមាន
- ចូលរួមពិនិត្យជាមួយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា លើសំណើសុំអនុញ្ញាតនាំចូលឧបករណ៍ សម្ភារៈបរិក្ខារ និងទំនិញផ្សេងទៀត សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតំបន់សេដ្ឋកិច្ចពិសេសរបស់អ្នកអភិវឌ្ឍន៍តំបន់

- គ្រប់គ្រងការទទួល ការបញ្ជូន និងការចែកចាយឯកសារផ្លូវការនានា ព្រមទាំងការងាររដ្ឋបាលផ្សេងទៀតរបស់នាយកដ្ឋាន
- គ្រប់គ្រងប្រាក់ពន្ធ ប្រាក់ផាកពិន័យ ប្រាក់រង្វាន់ និងរាល់ចំណូលផ្សេងទៀតរបស់នាយកដ្ឋាន ដែលប្រមូលបានតាមបទប្បញ្ញត្តិជាធរមាន
- កាន់កាប់រាល់សលាកប័ត្រ និងបញ្ជីគណនេយ្យ តែមប្រិ៍ និងឯកសារនានាដែលទាក់ទងនឹងការងារប្រមូលពន្ធរបស់នាយកដ្ឋាន
- ចាត់តាំងក្រុមអនុរក្ស និងក្រុមត្រួតពិនិត្យឃ្លាំមើលអនុលោមភាពនៃការអនុវត្តនីតិវិធីឆ្លងកាត់ទំនិញទៅមករវាងមាត់ច្រកព្រំដែន និងតំបន់រួចពន្ធនីមួយៗ អនុលោមភាពនៃការអនុវត្តគម្រោងវិនិយោគរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់ និងទប់ស្កាត់បង្ក្រាបនូវរាល់បទល្មើសគយនានា ពាក់ព័ន្ធនឹងរបបពន្ធ និងការបំពេញកាតព្វកិច្ចពន្ធ និងអាករដោយថាហេតុក្នុងតំបន់រួចពន្ធទាំងអស់
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

បណ្តាការិយាល័យគយ និងរដ្ឋាករគយប្រចាំតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- សម្របសម្រួលឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំការជាអចិន្ត្រៃយ៍ ជាមួយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ក្នុងការពិនិត្យ និងសម្រេចនៅនឹងកន្លែងនូវការលើកទឹកចិត្តលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មផ្សេងទៀត របស់អ្នកវិនិយោគក្នុងតំបន់
- គ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាព នៃការអនុវត្តភារកិច្ច និងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានផលិតកម្ម និងក្នុងពេលធ្វើអាជីវកម្ម
- គ្រប់គ្រង និងត្រួតពិនិត្យបែបបទគយ ពាក់ព័ន្ធនឹងការនាំចេញ ការនាំចូល និងការឆ្លងកាត់ទំនិញ និងមធ្យោបាយដឹកជញ្ជូនរបស់តំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ស្របតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធជាធរមាន ជាពិសេសច្បាប់ស្តីពីគយ នីតិវិធី

ពិសេសសម្រាប់អនុវត្តក្នុងតំបន់សេដ្ឋកិច្ចពិសេស ព្រមទាំងខ្លឹមសារនៃសិទ្ធិប្រទាន ឬការធ្វើប្រតិភូកម្មអំណាចនានាជាយថាហេតុ

- គ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ ចំពោះមុខទំនិញនានា ដែលជាប់ពន្ធ ក្នុងតំបន់សេដ្ឋកិច្ចពិសេស និងត្រូវចាត់តាំងក្រុមអនុរក្សដើម្បីឃ្លាំមើលអនុលោមភាពរបស់អ្នកអភិវឌ្ឍន៍តំបន់ អ្នកវិនិយោគក្នុងតំបន់ និងបុគ្គលពាក់ព័ន្ធផ្សេងទៀតនៃតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៣៥ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្ណាការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

*** ៧៧ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរគោរពចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួន ពីរ (០២) ដូចខាងក្រោម :

- ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ច ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យគ្រប់គ្រងបុគ្គលិក និងរដ្ឋបាល មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំ និងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយ និងរដ្ឋាករ។
- រៀបចំគ្រប់គ្រងស្ថិតិលើទិន្នន័យបុគ្គលិក និងតារាងព័ត៌មាន សកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការគយ និងរដ្ឋាករ។
- ចូលរួមរៀបចំការងារផ្លាស់ប្តូរ ផ្ទេរភារកិច្ច តម្លើងឋានៈ ឬបន្ថយឋានៈចំពោះមន្ត្រីរាជការគយ និងរដ្ឋាករ ក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- រៀបចំបៀវត្សន៍ ក្របខ័ណ្ឌ ប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ និងគ្រប់គ្រងគោលនយោបាយធានារ៉ាប់រងសង្គម និងរបបសំរាកលំហែ។
- គ្រប់គ្រងការចេញលិខិតឧទ្ទេសនាម ឬលិខិតបញ្ជាបេសកកម្មរបស់មន្ត្រីរាជការគយនិងរដ្ឋាករ។
- ចូលរួមរៀបចំគោលនយោបាយ លើកសរសើរ ផ្តល់កិត្តិយស ដាក់វិន័យ ស្តីបន្ទោស ឬព្រមានដល់មន្ត្រីគយ និងរដ្ឋាករ ដោយផ្អែកតាមច្បាប់ និងបទបញ្ញត្តិជាធរមាននានា។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

- ចាត់ចែង និងសហការរៀបចំទិវាបុណ្យជាតិ និងអន្តរជាតិនានា និងពិធីចាំបាច់ផ្សេងៗក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងស្ថិតិ ការប្រើប្រាស់អាវុធរបស់អង្គភាព។
- ចាត់ចែង រៀបចំ និងត្រួតពិនិត្យនូវការគោរពវិន័យការងារ ការថែរក្សាសណ្តាប់ធ្នាប់ សន្តិសុខ និងសុវត្ថិភាពក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាទាំងមូល។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤.-**

ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- ចូលរួមលើកគម្រោងផែនការប្រមូលចំណូលពន្ធ អាករគ្រប់ប្រភេទ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងតាមដានវិវឌ្ឍន៍ពីការប្រតិបត្តិ។
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា នីតិវិធីនានា បំរើឱ្យការងារគណនេយ្យពន្ធគយ។
- គ្រប់គ្រងបញ្ជីស្នាមពាក់ព័ន្ធនឹងប្រាក់ពន្ធលើទំនិញនាំចេញ នាំចូល ប្រាក់ផាកពិន័យ ប្រាក់រង្វាន់ ប្រាក់បំណុល ប្រាក់បៀវត្សន៍ និងរាល់ចំណូលផ្សេងៗទៀតដែលមាន។
- គ្រប់គ្រងការងារហិរញ្ញវត្ថុរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាជារួម ជាពិសេសតាមរយៈការប្រមូលផ្តុំតម្រូវការ និងធ្វើកម្មវិធីចំណាយរបស់អង្គភាពឱ្យបានទៀងទាត់ ដោយត្រូវគ្រប់គ្រងការធ្វើរបាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ និងធ្វើរបាយការណ៍សម្រេចទូទាត់ចំណូល ចំណាយថវិកាប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- គ្រប់គ្រងការទិញ ការបែងចែកមធ្យោបាយ សម្ភារបរិក្ខារនានាសំរាប់បំរើការងាររបស់អង្គភាព។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារ ធ្វើបញ្ជីសារពើភ័ណ្ឌ និងគ្រប់គ្រងការប្រើប្រាស់អាគារ ការរៀបចំជួសជុលផ្សេងៗរបស់អង្គភាព។
- តាមដាន វិលើក ការគ្រប់គ្រងគណនីពិសេស។
- កាន់កាប់រាល់សាលាកប័ត្រ និងបញ្ជីគណនេយ្យរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- បោះពុម្ពបង្កាន់ដៃពន្ធ ឯកសារបច្ចេកទេស បញ្ជីគណនេយ្យ ឯកសាររដ្ឋបាល តែមប្រើលតាប័ត្រយានយន្ត និងឯកសារនានា ដែលទាក់ទងនឹងការងារគយ និងរដ្ឋាករ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ /

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន</u> :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត- ក្រុងដែលពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១២៦៤ សហវ.ក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើត នាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបង្កើត និងដាក់ឲ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យ នៃនាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន កិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនពីរ (០២) ដូចខាងក្រោម ៖

- ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ
- ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋាន កិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- សហការស្រាវជ្រាវ និងផ្តល់យោបល់ ពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ
- ទទួលបន្ទុកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ និងការធ្វើវិសោធនកម្ម ឬការកែសម្រួលបទប្បញ្ញត្តិគយ

- ទទួលបន្ទុកពិនិត្យ និងចូលរួមពិនិត្យសំណើសុំបង្កើតតណ្ឌាគារគយមានដែនកំណត់ តំបន់រួចពន្ធ និងបណ្ដាអាជីវកម្មដ្ឋានប្រហាក់ប្រហែល និងចាត់ចែង គ្រប់គ្រង ត្រួតពិនិត្យ ទីកន្លែង និងសេវាកម្មទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងកិច្ចសន្យាជាធរមាននានា
- ទទួលបន្ទុកគ្រប់គ្រងកំណត់ហេតុបទល្មើសគយ និងមានភារកិច្ចសម្រុះសម្រួលបទល្មើសគយ និងវិវាទផ្សេងទៀត ដោយផ្ដល់យោបល់សម្រាប់បម្រើឲ្យការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានា ដាក់ជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ពិនិត្យ និងសម្រេច ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- តម្កល់ឯកសារ និងបទប្បញ្ញត្តិច្បាប់ជាធរមាននានា និងណែនាំដល់គ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អំពីរបៀបគ្រប់គ្រង ថែទាំឯកសារទាំងនេះ
- ទទួលពិនិត្យ និងវាយតម្លៃនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជន និងបុគ្គលពាក់ព័ន្ធនានា ក្នុងនាមជាអង្គភាពទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងគោលដៅរក្សាតុល្យភាពរវាងប្រសិទ្ធភាព នៃការអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ ត្រូវអនុវត្តតាមបញ្ញត្តិប្រកាសលេខ ៦០៧ សហវ.ប្រក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបង្កើត និងដាក់ឲ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយ និងរដ្ឋាករ និងមានមុខងារ និងភារកិច្ចបន្ថែមដូចតទៅ ៖

- ទទួលបន្ទុកជាអង្គភាពគ្រប់គ្រងជើងសារគយតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២៦៣ សហវ.ពបក

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

## ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ នៃនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួនបួន (០៤) ដូចខាងក្រោម ៖

- ការិយាល័យផែនការ និងគោលនយោបាយគយ
- ការិយាល័យបច្ចេកទេសគយ
- ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា
- ការិយាល័យកិច្ចការអន្តរជាតិ

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ចដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យផែនការនិងគោលនយោបាយគយ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- លើកសំណើគោលនយោបាយសមស្របពាក់ព័ន្ធនឹងពាណិជ្ជកម្មអន្តរជាតិ និងចូលរួមធ្វើសេចក្តីព្រាងបទបញ្ញត្តិ និងកំណត់ផែនការពាក់ព័ន្ធនឹងការងារប្រមូលពន្ធ និងអាករគ្រប់ប្រភេទឲ្យបានសមស្របទៅតាមតំណាក់កាលនីមួយៗនៃការវិវត្តន៍គោលនយោបាយសេដ្ឋកិច្ចរបស់រដ្ឋ។
- លើកឡើងនូវផែនការជាយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- សិក្សា និងវិភាគបណ្តាគោលនយោបាយសេដ្ឋកិច្ចនានា ពាក់ព័ន្ធនឹងគយ។
- ចូលរួមឃ្លាំមើល និងវាយតម្លៃការអនុវត្តន៍កិច្ចប្រតិបត្តិការគយ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៤.-**

ការិយាល័យបច្ចេកទេសគយ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រង កសាង និងតាមដានពិនិត្យការអនុវត្តន៍បទបញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងតារាងពន្ធគយ ការកំណត់តម្លៃគិតពន្ធគយ ឬអាករគយលើទំនិញនាំចេញ

នាំចូល ការវិវត្តនៃការកំណត់ដើមកំណើតទំនិញឲ្យបានទាន់ពេលវេលា និងស្រប តាមការវិវត្តន៍នៃសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ។

- ស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីយោងតម្លៃគិតពន្ធ ឬអាករគយ លើទំនិញនាំចេញ នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់តាមការកំណត់របស់ច្បាប់ និងបទបញ្ញត្តិជាធរមាន ព្រមទាំងចូលរួមត្រួតពិនិត្យ ផ្ទៀងផ្ទាត់មើលការអនុវត្តន៍នូវបណ្តាតារាង និងបញ្ជីទាំងនេះ។
- បំពេញតួនាទី ពិនិត្យ និងផ្តល់យោបល់លើការកំណត់តម្លៃគិតពន្ធ ឬអាករគយ ការកំណត់ដើមកំណើត និងការកំណត់ចំណាត់ថ្នាក់ទំនិញ និងចូលរួមផ្តល់យោបល់លើទិដ្ឋភាពបច្ចេកទេសគយពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥.-**

ការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា មានមុខងារ និងភារកិច្ចដូចតទៅ ៖

- កសាងយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជា ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។
- រៀបចំបទបញ្ញត្តិ និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា។
- រៀបចំគ្រប់គ្រងការស្រង់ប្រមូល និងរក្សាទិន្នន័យ និងស្ថិតិនៃការនាំចេញ នាំចូល។
- ប្រមូលផ្តុំទិន្នន័យទំនិញនាំចេញ នាំចូល ជាលក្ខណៈសង្ខេប ជាប្រចាំរាល់ដំណាច់ខែ ត្រីមាស ឆ្នាំនីមួយៗ។
- រៀបចំតភ្ជាប់បណ្តាញកុំព្យូទ័រនៅក្នុងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងគ្រប់គ្រងការប្រើប្រាស់ និងថែរក្សាបណ្តាញនេះ។
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល និងផ្នែកឯកជនក្នុងក្របខ័ណ្ឌនៃការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសម្រាប់បម្រើពាណិជ្ជកម្មអន្តរជាតិ ។
- ប្រមូលផ្តុំព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន ពាក់ព័ន្ធនឹងកិច្ចការគយ និងរដ្ឋាករដល់អាជីវករ និងអតិថិជន ដោយប្រើប្រាស់គ្រប់មធ្យោបាយ រួមទាំងមធ្យោបាយអេឡិចត្រូនិចផងដែរ ។
- សហការជាមួយអង្គការតំបន់ និងអន្តរជាតិ ព្រមទាំងរដ្ឋបាលគយនៃប្រទេសផ្សេងទៀតក្នុងការផ្លាស់ប្តូរព័ត៌មាន ការប្រើប្រាស់ និងអភិវឌ្ឍន៍បច្ចេកវិទ្យាព័ត៌មាន ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

ការិយាល័យកិច្ចការអន្តរជាតិ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- លើកឡើងនូវយុទ្ធសាស្ត្រ និងចក្ខុវិស័យគយ និងរដ្ឋាករកម្ពុជាក្នុងបរិបទសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងពិភពលោក។
- សិក្សា និងផ្តល់អនុសាសន៍ស្តីពីការចូលរួមប្រតិបត្តិការផ្នែកគយ នៅក្នុងអង្គការតំបន់ និងពិភពលោក ព្រមទាំងជម្រុញបង្កើនទំនាក់ទំនងទ្វេភាគី ជាមួយរដ្ឋបាលគយនៃប្រទេសផ្សេងៗ។
- តាមដាន និងសម្របសម្រួលការអនុវត្តន៍នូវរាល់កាតព្វកិច្ចរបស់កម្ពុជា ពាក់ព័ន្ធនឹងកិច្ចការគយ ក្រោមកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគី។
- វិភាគ វាយតម្លៃ និងផ្តល់អនុសាសន៍អំពីផលប៉ះពាល់ផ្សេងៗ ដែលអាចកើតមានឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីទាំងនោះ ជាពិសេសពាក់ព័ន្ធនឹងចំណូលពន្ធគយ ។
- សម្របសម្រួល និងចូលរួមសហការជាមួយស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ ។
- សហការជាមួយអង្គភាពពាក់ព័ន្ធនានា នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីស្រាវជ្រាវព័ត៌មាន ពាក់ព័ន្ធនឹងបទល្មើសគ្រប់ប្រភេទពីបណ្តាប្រកពក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងចូលរួមវិភាគ និងវាយតម្លៃហានិភ័យលើព័ត៌មានទាំងនេះ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**មាត្រា ៧.-**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ក្រុងដែលពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: [illegible] សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ [illegible] ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃ នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

*** ២៧ ***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងកំណត់នូវមុខងារ និងភារកិច្ចរបស់បណ្តាការិយាល័យទាំងនេះ។

**ប្រការ ២.-**

ត្រូវបានកំណត់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នូវការិយាល័យចំនួន បី (០៣) ដូចខាងក្រោម :

- ការិយាល័យគោលនយោបាយរដ្ឋាករ និងគ្រប់គ្រង
- ការិយាល័យគ្រប់គ្រងផលិតផលគេលសិលា និងថាមពល
- ការិយាល័យបង្ការ បង្ក្រាបបទល្មើស និងគ្រប់គ្រងផលិតកម្ម

បណ្តាការិយាល័យនីមួយៗរបស់នាយកដ្ឋានរដ្ឋាករ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ដែលទទួលខុសត្រូវតាមភារកិច្ច ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាកំណត់។

**ប្រការ ៣.-**

ការិយាល័យគោលនយោបាយរដ្ឋាករ និងគ្រប់គ្រង មានមុខងារ និងភារកិច្ចដូចតទៅ :

- លើកឡើងនូវសំណើគោលនយោបាយ ពាក់ព័ន្ធនឹង ពន្ធអាករ ការគ្រប់គ្រងផលិតកម្ម ការនាំចេញនាំចូល ការធ្វើចរាចរចែកចាយ ការធ្វើសន្និធិផលិតផលគេលសិលា និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- កសាងនូវផែនការមេ និងផែនការសកម្មភាពសំរាប់អភិវឌ្ឍន៍វិស័យរដ្ឋាករ និងសំរាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរបបគយនីមួយៗរបស់អង្គភាពគយ និងរដ្ឋាករ ។
- គ្រប់គ្រងកិច្ចដំណើរការរបស់អាគារលក់ទំនិញរួចពន្ធនៅទូទាំងប្រទេស ។
- ទទួលបន្ទុកការងារគ្រប់គ្រងរដ្ឋបាល ស្ថិតិ និងគណនេយ្យរបស់នាយកដ្ឋានរដ្ឋាករ ។
- គ្រប់គ្រងការចេញលិខិតអនុញ្ញាតនាំចេញ- នាំចូល និងប័ណ្ណសំគាល់មធ្យោបាយដឹកជញ្ជូនផលិតផលគេលសិលាគ្រប់ប្រភេទ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានរដ្ឋាករ ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីពាក់ព័ន្ធការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤.-**

ការិយាល័យគ្រប់គ្រងផលិតផលគេលសិលា និងថាមពល មានមុខងារ និងភារកិច្ចដូចតទៅ :

- គ្រប់គ្រង ត្រួតពិនិត្យបែបបទគយនាំចេញ- នាំចូល លើផលិតផលគេលសិលា និងថាមពល តាមបទបញ្ញត្តិច្បាប់ជាធរមាន។
- គ្រប់គ្រង ត្រួតពិនិត្យ វាស់វែង តាមដានការដឹកជញ្ជូន ចរាចរចែកចាយ ការបញ្ចេញបញ្ចូល ជាពិសេសទទួលបន្ទុកគ្រប់គ្រងការចេញលិខិតអនុញ្ញាតដឹកជញ្ជូនផលិតផលគេលសិលា នៅតាមមណ្ឌលឃ្លាំង ឬអាជីវកម្មដ្ឋាននានានៅទូទាំងប្រទេស តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៥.-**

ការិយាល័យបង្ការ បង្ក្រាបបទល្មើស និងគ្រប់គ្រងផលិតកម្ម មានមុខងារ និងភារកិច្ចដូចតទៅ :

- សហការជាមួយអង្គភាពគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត កសាងគោលនយោបាយបំរើឱ្យការស្រាវជ្រាវ បង្ការ និងបង្ក្រាបបទល្មើសពាក់ព័ន្ធនឹងអាជីវកម្មផលិតផលគេលសិលា និងថាមពល។
- ចាត់វិធានការស្រាវជ្រាវ បង្ការ និងបង្ក្រាបអំពើល្មើសពាក់ព័ន្ធនឹងអាជីវកម្មផលិតផលគេលសិលា នៅទូទាំងដែនគយ នៃព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមបទបញ្ញត្តិច្បាប់ជាធរមាន និងតាមបទបញ្ជារបស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា។
- សហការជាមួយអង្គភាពគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីប្រមូល ផ្លាស់ប្តូរ និងបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពមិនប្រក្រតីនានាលើបុគ្គល មធ្យោបាយដឹកជញ្ជូន និងល្បិចល្មើសគ្រប់ប្រភេទលើមុខទំនិញផលិតផលគេលសិលា និងថាមពល។
- គ្រប់គ្រង និងត្រួតពិនិត្យកិច្ចដំណើរការផលិតកម្មក្នុងស្រុកនូវផលិតផលគេលសិលា ជីវឥន្ធនៈ និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- គ្រប់គ្រងធនធានមនុស្ស និងសកម្មភាពប្រតិបត្តិរបស់មន្ត្រីរាជការក្រោមឱវាទ ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៦.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចម្លងជូន</u> :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលារាជធានី
- គ្រប់សាលាខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៥៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ**

**និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## <u>សម្រេច</u>

**មាត្រា ១.-**

បង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និង នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អង្គការលេខរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រោយពីការបង្កើតនាយកដ្ឋានទាំង ៣ ខាងលើ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

នាយកដ្ឋានរដ្ឋាករមានភារកិច្ចដូចតទៅ ៖

- លើកឡើងនូវគោលនយោបាយពន្ធ និងអាករ ការគ្រប់គ្រងផលិតកម្ម ការនាំចេញ-នាំចូល ការធ្វើចរាចរចែកចាយ ឬការធ្វើសន្និធិផលិតផលតេលសិលា និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កសាងនូវផែនការមេ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍវិស័យរដ្ឋាករ និងសម្រាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរបបគយនីមួយៗរបស់អង្គភាពគយ និងរដ្ឋាករ
- គ្រប់គ្រង ត្រួតពិនិត្យបែបបទនាំចេញ-នាំចូល ការប្រមូលពន្ធ និងអាករ ការចែកចាយ ការដឹកជញ្ជូន ចរាចរ សន្និធិផលិតផលតេលសិលានៅទូទាំងប្រទេស នៅតាមមណ្ឌលឃ្លាំង ឬអាជីវកម្មដ្ឋានផ្សេងៗ
- គ្រប់គ្រងកិច្ចដំណើរការរបស់បណ្តាអាជីវកម្មដ្ឋានផលិតទំនិញជាប់អាករពិសេស ហាងលក់ទំនិញរួចពន្ធ ការធ្វើបែបបទគណ្ឌិកាប្រៃសណីយ៍ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសគយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មទាំងនេះ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានរដ្ឋាករ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៣.-**

នាយកដ្ឋានរបបគយ មានភារកិច្ចដូចតទៅ ៖

- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រង សកម្មភាពវិនិយោគ និងសកម្មភាពនាំចេញ-នាំចូលទំនិញរបស់អង្គការ ស្ថានទូត ស្ថាប័នរដ្ឋ និងបុគ្គលផ្សេងៗទៀតតាមរបបគយអនុគ្រោះ
- ត្រួតពិនិត្យ និងគ្រប់គ្រងការចេញលិខិតអនុញ្ញាតនាំចេញ-នាំចូលទំនិញតាមរបបគយអនុគ្រោះនានា តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដាន ត្រួតពិនិត្យការប្រើប្រាស់សម្ភារៈ បរិក្ខារ និងទំនិញគ្រប់ប្រភេទ ដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់

- ចាត់ចែងត្រួតពិនិត្យជាក្រោយលើប្រតិវេទន៍គយ និងឯកសារភ្ជាប់ ហើយសរុបលទ្ធផល និងលើកឡើងនូវវិធានការសមស្របក្នុងករណីចាំបាច់
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានរបបគយ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៤.-**

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធមានភារកិច្ចដូចតទៅ ៖

- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រងកិច្ចដំណើរការតំបន់រួចពន្ធនានា នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសបណ្តាតំបន់សេដ្ឋកិច្ចពិសេសទាំងអស់ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ការអនុវត្តល្អបំផុតជាអន្តរជាតិ និងអនុសញ្ញាទីក្រុងក្យូតូស្តីពីការធ្វើឲ្យសាមញ្ញ និងស៊ីចង្វាក់នៃនីតិវិធីគយ សំដៅជានាឲ្យបាននូវភាពរលូន និងឆាប់រហ័សក្នុងការបំពេញបែបបទលើទំនិញចេញ និងចូលតំបន់ទាំងនេះ
- ចូលរួមពិនិត្យជាមួយគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា លើសំណើសុំអនុញ្ញាតនាំចូលឧបករណ៍ សម្ភារៈបរិក្ខារ និងទំនិញផ្សេងទៀត សម្រាប់ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធតំបន់សេដ្ឋកិច្ចពិសេសរបស់អ្នកអភិវឌ្ឍន៍តំបន់
- សម្របសម្រួលឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់មន្ត្រីគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំការជាអចិន្ត្រៃយ៍ ជាមួយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស ក្នុងការពិនិត្យ និងសម្រេចនៅនឹងកន្លែងនូវការលើកទឹកចិត្តលើការនាំចូលសម្ភារៈបរិក្ខារផលិតកម្ម សម្ភារៈសាងសង់ និងធាតុចូលផលិតកម្មផ្សេងទៀត របស់អ្នកវិនិយោគក្នុងតំបន់
- គ្រប់គ្រង ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់អនុលោមភាព នៃការអនុវត្តភារកិច្ច និងកាតព្វកិច្ចរបស់អ្នកអភិវឌ្ឍន៍តំបន់ និងអ្នកវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស ក្នុងពេលសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានផលិតកម្ម និងក្នុងពេលធ្វើអាជីវកម្ម
- គ្រប់គ្រង និងដឹកនាំបញ្ជាតាមឋានានុក្រមដោយផ្ទាល់លើអង្គភាពគយ និងរដ្ឋាករមានសមត្ថកិច្ចប្រចាំការតាមតំបន់រួចពន្ធ ឬតំបន់សេដ្ឋកិច្ចពិសេស
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៥.-**

នាយកដ្ឋានរដ្ឋាករ និងរបបគយ ដូចមានចែងក្នុងបញ្ញត្តិមាត្រា ៤ និងមាត្រា ៧ នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋាន

គយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានជំនួសដោយ នាយកដ្ឋានរដ្ឋាករ និងនាយកដ្ឋានរបបគយ ដូចមានចែងក្នុងបញ្ញត្តិមាត្រា ១ មាត្រា ២ និងមាត្រា ៣ ខាងលើ នៃអនុក្រឹត្យនេះ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ៣ ឆ្នាំ ២០០៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**<u>ចម្លងជូន</u> ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង និងរាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៤៤ អនក្រ.បក ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៨

# អង្គការលេខរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ..១៣៤...អនក្រ-បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី២
## អំពីបេសកកម្ម ភារកិច្ច និង រចនាសម្ព័ន្ធ

### ផ្នែកទី១
### អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា

មាត្រា ២.-

អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា មានបេសកកម្មដូចតទៅ÷

- ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលពន្ធ អាករ និង កម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិផ្សេងទៀត ដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និង ការធ្វើសន្និធិទំនិញ
- ដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬនាំចូល
- ជម្រុញការបង្ការ និង ការបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ
- ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- ជម្រុញការអនុវត្តតាមស្តង់ដារអន្តរជាតិ និង ការអនុវត្តល្អប្រសើរ ដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយ និង ការសម្រួលពាណិជ្ជកម្ម ជាពិសេសការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ ។

មាត្រា ៣.-

អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា មានភារកិច្ចធ្វើជាសេនាធិការអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលើការងារដូចតទៅ÷

- លើកសំណើគោលនយោបាយ ដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរពាណិជ្ជកម្មអន្តរជាតិ ព្រាងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងការងារប្រមូលពន្ធ និង អាករនាំចេញ-នាំចូលគ្រប់ប្រភេទ ជាពិសេសពិនិត្យពិចារណា ក្នុងការកសាងនិងអនុវត្តតារាងពន្ធគយនិងនីតិវិធីទាំងឡាយ ដែលទាក់ទងនឹងការងារគយ និង រដ្ឋាករ លើមុខទំនិញគ្រប់ប្រភេទអោយបានសមស្របទៅតាមដំណាក់កាលនីមួយៗ នៃការវិវត្តសេដ្ឋកិច្ច
- ជាស្ថាប័ននាំមុខតែមួយគត់ ដែលទទួលខុសត្រូវលើការត្រួតពិនិត្យទំនិញនាំចេញឬនាំចូលនៅមាត់ច្រកព្រំដែន និង មានភារកិច្ចសម្របសម្រួលអោយមានការត្រួតពិនិត្យរួមគ្នាតែមួយលើកក្នុងករណី ដែលតម្រូវអោយមានការត្រួតពិនិត្យដោយស្ថាប័នផ្សេងទៀតស្របតាមការកំណត់រកឃើញហានិភ័យ
- គ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូលគ្រប់ប្រភេទ
- លើកវិធានការរាំងខ្ទប់ និងចាប់យាត់ទំនិញរត់ពន្ធគយគ្រប់ប្រភេទ
- ត្រួតពិនិត្យ តាមដាន និងគ្រប់គ្រងការនាំចេញ-នាំចូលទំនិញគ្រប់ប្រភេទ ទោះមាន ឬគ្មានលក្ខណៈពាណិជ្ជកម្មក្តី ដោយរាប់បញ្ចូលទាំងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកដំណើរឬផ្លាស់ប្តូរលំនៅដ្ឋាន រូបិយប័ណ្ណ លោហធាតុ-ត្បូងថ្មមានតម្លៃ បេតិកភណ្ឌវប្បធម៌ និងភណ្ឌិកាប្រៃសណីយ៍ ព្រមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ
- លើកគម្រោងជ្រើសរើស និងបណ្តុះបណ្តាលជំនាញបច្ចេកទេស មន្ត្រី បុគ្គលិក និងភ្នាក់ងារគយ និង រដ្ឋាករ
- អនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ច និង សហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងការងារគយ និងរដ្ឋាករ
- ចូលរួមរៀបចំគម្រោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងប្រចាំឆ្នាំនីមួយៗ
- អនុវត្តនូវភារកិច្ចផ្សេងទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា មានប្រព័ន្ធចាត់តាំងគ្រប់គ្រងឯកភាពទូទាំងប្រទេស មានសិទ្ធិដឹកនាំ និង ត្រួតពិនិត្យលើរាល់អង្គភាពគយ និង រដ្ឋាករពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋានខេត្ត-ក្រុង តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករង មួយចំនួន ជាជំនួយការ ។

**មាត្រា ៤.-**

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មាននាយកដ្ឋានក្រោមឱវាទចំនួន ៥ និងលេខាធិការដ្ឋាន មួយនៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានមួយចំនួនដូចខាងក្រោម ÷

**ក- ថ្នាក់កណ្តាល ÷**

- នាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង
- នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ
- នាយកដ្ឋានរដ្ឋាករ និងរបបគយ
- នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ
- នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស
- លេខាធិការដ្ឋាន

**ខ- អង្គភាពមូលដ្ឋាន ÷**

រួមមានសាខាគយ និង រដ្ឋាករខេត្ត-ក្រុង ការិយាល័យគយ និងរដ្ឋាករ ក្រុមត្រួតពិនិត្យបែបបទគយ និងបណ្តាទីស្នាក់ការគយ និងរដ្ឋាករ ។

អង្គការលេខរបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ ។

**មាត្រា ៥.-**

នាយកដ្ឋានរដ្ឋបាល និង គ្រប់គ្រង មានភារកិច្ចដូចតទៅ ÷

- រៀបចំ និងចាត់ចែងការងារគ្រប់គ្រងមន្ត្រីរាជការគយ និង រដ្ឋាករ ដែលរាប់បញ្ចូលទាំង ការគ្រប់គ្រងស្ថិតិ អនុលោមភាព ការផ្លាស់ប្តូរ-ផ្ទេរភារកិច្ច និងឋានៈ ការលើកសរសើរ ឬ ដាក់វិន័យ និងការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងក្របខ័ណ្ឌបៀវត្សរ៍ ប្រាក់កម្រៃ របប ឧបត្ថម្ភ និងរបបសម្រាកលំហែផ្សេងៗ
- រៀបចំនិងចាត់ចែងការងារបណ្តុះបណ្តាលមន្ត្រីរាជការគយនិងរដ្ឋាករ ក៏ដូចជាមន្ត្រីរាជការនៃ អង្គភាពពាក់ព័ន្ធផ្សេងទៀត ព្រមទាំងផ្នែកឯកជនផងដែរ ក្នុងករណីចាំបាច់
- គ្រប់គ្រងការទទួល ការបញ្ជូន និងការចែកចាយឯកសារផ្លូវការផ្សេងៗ
- ទទួលបន្ទុកការងាររដ្ឋបាលផ្សេងទៀត រាប់បញ្ចូលទាំងការកសាងរបាយការណ៍ ការវាយតំលៃ ប្រសិទ្ធភាពការងារ និងការចេញលិខិតឧទ្ទេសនាម ឬលិខិតបញ្ជាបេសកកម្មផ្សេងៗ

- គ្រប់គ្រងស្ថិតិការប្រើប្រាស់អាវុធក្នុងអង្គភាព
- ទទួលខុសត្រូវ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ពាក់ព័ន្ធនឹង ហិរញ្ញវត្ថុ គណនេយ្យ ការចូលរួមកសាង និងត្រួតពិនិត្យការអនុវត្តផែនការចំណូល- ចំណាយ ការទូទាត់នានា ការគ្រប់គ្រងតម្រូវការ ការទិញ ការបែងចែក និងការថែរក្សាសម្ភារៈ និងបរិក្ខារ ព្រមទាំងទ្រព្យសម្បត្តិផ្សេងៗរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានរដ្ឋបាល និង គ្រប់គ្រង ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា ៦.-**

នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិមានភារកិច្ចដូចតទៅ÷
- លើកឡើងនូវគោលនយោបាយសមស្រប ពាក់ព័ន្ធនឹងនីតិវិធីនៃការប្រមូលពន្ធ និង អាករ ការកំណត់គោលដៅប្រមូលចំណូល និង ការកសាងនូវផែនការមេ និងផែនការសកម្មភាព របស់អង្គភាពគយនិងរដ្ឋាករ
- គ្រប់គ្រងការកសាង ការស្រាវជ្រាវ និងចូលរួមតាមដានត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ និង គោលនយោបាយទាំងឡាយ ដែលពាក់ព័ន្ធនឹងតារាងពន្ធគយ ការកំណត់តម្លៃគិតពន្ធគយ ឬ អាករគយលើទំនិញនាំចេញ- នាំចូល ការវិវត្តនៃការកំណត់ដើមកំណើតទំនិញអោយបានទាន់ ពេលវេលា និងស្របតាមការវិវត្តនៃសេដ្ឋកិច្ចជាតិ និងពាណិជ្ជកម្មអន្តរជាតិ ដោយរាប់បញ្ចូល ទាំងការកែសម្រួលចំណាត់ថ្នាក់ទំនិញ ការវាយតម្លៃផលប៉ះពាល់ពីការកែសម្រួលនានា ការកសាង វិធីសាស្ត្រវិភាគ និងគ្រប់គ្រងមន្ទីរពិសោធន៍គយនានា
- កសាង និង គ្រប់គ្រងការអនុវត្តនូវផែនការអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានវិទ្យាគយ ជាពិសេស ពាក់ព័ន្ធនឹងការធ្វើស្វ័យប្រវត្តិកម្មនីតិវិធីគយ ព្រមទាំងការគ្រប់គ្រងស្រង់ ប្រមូល និង រក្សា ទិន្នន័យ ស្ថិតិនាំចេញ- នាំចូល ដោយរាប់បញ្ចូលទាំងការគ្រប់គ្រងការប្រើប្រាស់ និង ថែរក្សា ប្រព័ន្ធទាំងនេះ
- ស្រាវជ្រាវនិងកែសម្រួលជាប្រចាំនូវបញ្ជីតម្លៃគិតពន្ធ ឬ អាករគយសម្រាប់ពិចារណាលើទំនិញ នាំចេញ- នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់អោយបានសមស្របតាមភាពជាក់ស្តែងសំរាប់ ជាមូលដ្ឋានពិចារណានិងសម្រេចចិត្តក្នុងការអនុវត្តការងាររបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋាន

- បំពេញតួនាទី ពិនិត្យ និងផ្តល់យោបល់លើការងារពាក់ព័ន្ធនឹងបច្ចេកទេសគយ ជាពិសេសលើការងារកំណត់តម្លៃគិតពន្ធគយ ដើមកំណើត និងចំណាត់ថ្នាក់ទំនិញ និងចូលរួមធ្វើសវនកម្មលើការងារខាងលើនេះ ព្រមទាំងការងារជម្រះបញ្ជីផ្សេងៗទៀត
- បំពេញតួនាទីជាមជ្ឈមណ្ឌលកិច្ចការអន្តរជាតិ ពាក់ព័ន្ធនឹងវិស័យគយជារួម
- សិក្សានិងវិភាគព័ត៌មានពាក់ព័ន្ធនឹងសេដ្ឋកិច្ច និង ពាណិជ្ជកម្មអន្តរជាតិ ដោយប្រៀបធៀបជាមួយនឹងទិន្នន័យរបស់រដ្ឋបាលគយនៃប្រទេសជាដៃគូពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោក
- សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយអង្គការគយពិភពលោក រដ្ឋបាលគយផ្សេងទៀត និងជាមួយអង្គការនានាដែលពាក់ព័ន្ធនឹងវិស័យគយ
- សម្របសម្រួល និង ចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ
- ចូលរួមឃ្លាំមើល និងវាយតម្លៃប្រសិទ្ធភាពនៃប្រតិបត្តិការគយ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា ៧.-**

នាយកដ្ឋានរដ្ឋាករ និងរបបគយ មានភារកិច្ចដូចតទៅ ÷

- លើកឡើងនូវគោលនយោបាយពន្ធ និងអាករ ការគ្រប់គ្រងផលិតកម្ម ការនាំចេញ-នាំចូល ការធ្វើចរាចរចែកចាយ ឬការធ្វើសន្និធិផលិតផលគេលសិលា និងផលិតផលជាប់អាករពិសេសផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កសាងនូវផែនការមេ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍វិស័យរដ្ឋាករ និង សម្រាប់កិច្ចសម្រួលពាណិជ្ជកម្មតាមរបបគយនីមួយៗរបស់អង្គភាពគយ និងរដ្ឋាករ
- គ្រប់គ្រង ត្រួតពិនិត្យបែបបទនាំចេញ-នាំចូល ការប្រមូលពន្ធ និង អាករ ការចែកចាយ ការដឹកជញ្ជូន ចរាចរ សន្និធិផលិតផលគេលសិលានៅទូទាំងប្រទេស នៅតាមមណ្ឌលឃ្លាំង ឬអាជីវកម្មដ្ឋានផ្សេងៗ
- គ្រប់គ្រងកិច្ចដំណើរការរបស់បណ្តាអាជីវកម្មដ្ឋានផលិតទំនិញជាប់អាករពិសេស ហាងលក់ទំនិញរួចពន្ធ ការធ្វើបែបបទភណ្ឌិកាប្រៃសណីយ៍ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ស្រាវជ្រាវ និង បង្ក្រាបបទល្មើសគយពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្មទាំងនេះ

- ចូលរួមរៀបចំគោលនយោបាយគ្រប់គ្រងសកម្មភាពវិនិយោគឯកជន និងសកម្មភាពនាំចេញ-នាំចូលទំនិញរបស់អង្គការ ស្ថានទូត ស្ថាប័នរដ្ឋ និងបុគ្គលផ្សេងៗទៀតតាមរបបគយអនុគ្រោះ
- ត្រួតពិនិត្យ និង គ្រប់គ្រងការចេញលិខិតអនុញ្ញាតនាំចេញ- នាំចូលទំនិញ តាមរបបគយអនុគ្រោះនានា តាមការកំណត់របស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ព្រមទាំងមានភារកិច្ចតាមដានត្រួតពិនិត្យការប្រើប្រាស់សម្ភារៈ បរិក្ខារ និង ទំនិញគ្រប់ប្រភេទ ដែលទទួលបានការអនុគ្រោះនានាតាមទិសដៅដែលបានកំណត់
- ចាត់ចែងត្រួតពិនិត្យជាក្រោយលើប្រតិវេទន៍គយ និង ឯកសារភ្ជាប់ ហើយសរុបលទ្ធផល និងលើកឡើងនូវវិធានការសមស្របក្នុងករណីចាំបាច់
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានរដ្ឋាករ និង របបគយ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ៨. -**

នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ÷
- សហការស្រាវជ្រាវ និង ផ្តល់យោបល់ ពាក់ព័ន្ធនឹងការកសាងបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ
- ទទួលបន្ទុកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិគយនានា ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀត ដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការគយ និងការធ្វើវិសោធនកម្ម ឬការកែសម្រួលបទប្បញ្ញត្តិគយ
- ទទួលបន្ទុកពិនិត្យ និង ចូលរួមពិនិត្យសំណើសុំបង្កើតភណ្ឌាគារគយមានដែនកំណត់តំបន់រួចពន្ធ សេវាកម្មជើងសារគយ និងបណ្តាអាជីវកម្មដ្ឋានប្រហាក់ប្រហែល និងចាត់ចែងគ្រប់គ្រងត្រួតពិនិត្យទីកន្លែង និងសេវាកម្មទាំងនេះ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និង កិច្ចសន្យាជាធរមាននានា
- សម្រុះសម្រួលបទល្មើសគយ និង វិវាទផ្សេងទៀត ដោយផ្តល់យោបល់សម្រាប់បម្រើអោយការវិនិច្ឆ័យរាល់អំពើល្មើសច្បាប់គយនានា ដាក់ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ពិនិត្យនិងសម្រេច ស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីគយ
- ទទួលពិនិត្យ និង វាយតម្លៃនូវរាល់ការតវ៉ានានារបស់ផ្នែកឯកជននានា ក្នុងនាមជាអង្គភាពទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងគោលដៅរក្សាតុល្យភាពរវាងប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិច្បាប់ជាធរមាន និងកិច្ចសម្រួលពាណិជ្ជកម្មអន្តរជាតិ

- កសាង និងត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងហានិភ័យ ដើម្បីកំណត់មុខសញ្ញាដែលមានហានិភ័យខ្ពស់
- ប្រមូល វិភាគ វាយតម្លៃ និងគ្រប់គ្រងព័ត៌មាន និង ទិន្នន័យពីប្រភពនានាបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន និង ប្រព័ន្ធគ្រប់គ្រងលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ
- តាមដានការអនុវត្តកិច្ចព្រមព្រៀងអន្តរស្ថាប័នជាមួយនឹងភ្នាក់ងាររាជរដ្ឋាភិបាលផ្សេងទៀត ដោយអនុលោមតាមគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- កសាងផែនការ និង ចាត់ចែងធ្វើសវនកម្មលើអាជីវកម្មដ្ឋាន ដែលមានហានិភ័យខ្ពស់នានាតាមការកំណត់របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

**មាត្រា ៩.-**

នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស មានភារកិច្ចដូចតទៅ÷

- សហការកសាងគោលនយោបាយបម្រើអោយការស្រាវជ្រាវ និង បង្ក្រាបអំពើរត់ពន្ធ និងគេចពន្ធគ្រប់ប្រភេទ និងបទល្មើសផ្សេងទៀតនៅទូទាំងដែនគយ
- ចាត់តាំងបណ្តាញស្រាវជ្រាវសម្ងាត់ និងកម្លាំងពិសេសសម្រាប់ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើសច្បាប់គយ និងអំពើល្មើសផ្សេងទៀត
- រក្សាទុកទំនិញ ដែលឃាត់ទុកបណ្តោះអាសន្ន រង់ចាំការសម្រេចវិនិច្ឆ័យជាស្ថាពរពីអង្គការមានសមត្ថកិច្ចនានា និងចាត់ចែងទំនិញទាំងនេះតាមមុខសញ្ញាដែលបានកំណត់
- ចាត់តាំងក្រុមប្រតិបត្តិការស្រាវជ្រាវ និង បង្ក្រាបអំពើរត់ពន្ធ ធ្វើសកម្មភាពតាមគោលដៅសំខាន់ៗ ចាំបាច់នៅទូទាំងប្រទេស តាមបទបញ្ជាផ្ទាល់របស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ជាមជ្ឈមណ្ឌលសហប្រតិបត្តិការ និង គ្រប់គ្រង ប្រមូល ចងក្រងរាល់ព័ត៌មានពាក់ព័ន្ធនឹងទំនិញ បុគ្គល មធ្យោបាយដឹកជញ្ជូន និង ល្បិចល្មើសគ្រប់ប្រភេទពីបណ្តាប្រភពក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងធ្វើការវិភាគ និងវាយតម្លៃហានិភ័យលើព័ត៌មានទាំងនេះ សម្រាប់បម្រើអោយការងារបង្ក្រាបអំពើរត់ពន្ធ និង បទល្មើសផ្សេងទៀតរបស់ស្ថាប័នមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា និង សមភាគីបរទេសផងដែរ
- បំពេញបេសកកម្មផ្សេងទៀត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នាយកដ្ឋានបង្ការ និងបង្ក្រាបបទល្មើស ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

មាត្រា ១០.-

លេខាធិការដ្ឋានថ្នាក់កណ្តាល ជាលេខាធិការផ្ទាល់អមអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា មានភារកិច្ចដូចតទៅ÷

- ស្រាវជ្រាវ ពិនិត្យ សិក្សា ធ្វើរបាយការណ៍ និង ជូនយោបល់ជាប្រចាំលើរាល់ការងារចាំបាច់នានា ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- រៀបចំ តាក់តែង ចងក្រង ថែរក្សានូវបណ្តាឯកសារនានាតាមការចាំបាច់របស់អគ្គនាយក នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- ត្រួតពិនិត្យបណ្តាឯកសារ សេចក្តីព្រាងសំណើ សំណុំលិខិតផ្សេងៗ ឬកំណត់បង្ហាញមតិនានា មុននឹងបញ្ជូនទៅសុំការសម្រេចពីថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា
- រៀបចំ គ្រប់គ្រងការងារសវនកម្មផ្ទៃក្នុងអង្គភាពគយ និងរដ្ឋាករ និងបំពេញបេសកកម្មផ្សេងទៀត តាមការកំណត់ជាក់ស្តែងរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ។

លេខាធិការដ្ឋានថ្នាក់កណ្តាល ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

## ផ្នែកទី២

## អគ្គនាយកដ្ឋានពន្ធដារ

មាត្រា ១១.-

អគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មធ្វើឱ្យសំរេចនូវការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ តាមការ÷

- ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- អនុវត្តកម្មវិធីចាប់បង្ខំ ដោយការធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារនិងអនុវត្តទោសទណ្ឌតាមការកំណត់ នៃបទប្បញ្ញត្តិស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ
- ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាអោយច្បាប់នានាស្តីពីពន្ធដារត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ
- អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នាចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ
- អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្តចំពោះរដ្ឋបាលសារពើពន្ធ
- បន្ថយការចំណាយរបស់រដ្ឋបាលសារពើពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ខ្លួនធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ
- បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើការការងារ និងប្រព័ន្ធការងារ ដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន ។

**មាត្រា ១២.-**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចជាអាទិ៍ដូចតទៅ÷

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការអង្កេត និងជុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម ពន្ធប្រថាប់ត្រា ការប្រាក់ និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ។

អគ្គនាយកដ្ឋានពន្ធដារ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការ ។

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានពន្ធដារ ជារដ្ឋបាលសារពើពន្ធ មានប្រព័ន្ធចាត់តាំងឯកភាព ទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៤ .-**

អគ្គនាយកដ្ឋានពន្ធដារ រួមមាននាយកដ្ឋានចំណុះចំនួន ៧ នៅថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋាន ដូចខាងក្រោម÷

**ក-ថ្នាក់កណ្តាល ÷**

- នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ
- នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ
- នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ
- នាយកដ្ឋានត្រួតពិនិត្យ
- នាយកដ្ឋានព័ត៌មានវិទ្យា
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានសវនកម្មសហគ្រាស

**ខ-អង្គភាពមូលដ្ឋាន ÷**

- នៅខេត្ត-ក្រុងនីមួយៗ មានសាខាពន្ធដារខេត្ត-ក្រុង ដែលដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួន ជាជំនួយការ
- នៅស្រុក- ខ័ណ្ឌ មានស្នាក់ការពន្ធដារស្រុក- ខ័ណ្ឌ "ថ្នាក់ស្មើការិយាល័យពន្ធដារខេត្ត- ក្រុង"
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចកំណត់បង្កើតសាខាពន្ធដារខ័ណ្ឌ នៃរាជធានីភ្នំពេញ និងក្រុងមួយចំនួនទៀត "ថ្នាក់ស្មើសាខាពន្ធដារខេត្ត- ក្រុង" តាមការចាំបាច់ ។

អង្គការលេខរបស់អគ្គនាយកដ្ឋានពន្ធដារ ជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

មាត្រា ១៥.-

នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ÷

- រៀបចំ និងអនុវត្តគោលនយោបាយ និងនីតិវិធី ដើម្បីថែរក្សាសំណុំឯកសារមន្ត្រីពន្ធដារ និងតាមពិនិត្យការងារ លើកសរសើរ ដាក់ពិន័យ និងគាំពារមន្ត្រីពន្ធដារ
- រៀបចំប្រាក់បៀវត្ស និងក្របខ័ណ្ឌប្រាក់កំរៃ និងរបបឧបត្ថម្ភបន្ទុកគ្រួសារ គោលនយោបាយធានារ៉ាប់រងសង្គម របបសោធននិវត្តន៍ និងធ្វើការតម្លើងកាំប្រាក់បៀវត្សប្រចាំឆ្នាំ គ្រប់គ្រងស្ថិតិ និងឥណទានបៀវត្សមន្ត្រីប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនមន្ត្រីពន្ធដារ
- រៀបចំសំណើទៅថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិនិត្យ និងសំរេច ស្តីពីការតែងតាំង ផ្លាស់ប្តូរ លុបឈ្មោះចេញពីក្របខ័ណ្ឌ ស៊ុំឈប់ពីការងារ និងដាក់ឱ្យចូលនិវត្តន៍របស់មន្ត្រីពន្ធដារ
- រៀបចំគោលនយោបាយ ធ្វើផែនការក្របខ័ណ្ឌ ជ្រើសរើស និងបណ្តុះបណ្តាលមន្ត្រីពន្ធដារ
- ជំនួយផ្នែករដ្ឋបាលប្រចាំថ្ងៃដោយផ្ទាល់ ទៅអគ្គនាយក និងអគ្គនាយករងទាំងអស់
- រៀបចំគោលនយោបាយ នីតិវិធី និងសេចក្តីណែនាំដែលចាំបាច់ក្នុងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ
- បង្កើតប្រព័ន្ធដើម្បីបែងចែកនិងប្រគល់រាល់ឯកសារលិខិតស្នាមទាំងអស់ ដែលមានប្រភពពីក្នុង និងក្រៅអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំ និងគ្រប់គ្រងបណ្ណាល័យ ថែរក្សា ការពារ ជួសជុល ទ្រព្យសម្បត្តិរបស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានល្អ
- ស្នើសុំនិងបើកផ្តល់ថវិកាសំរាប់ផ្គត់ផ្គង់រាល់មធ្យោបាយ និងសម្ភារៈចាំបាច់សំរាប់បំពេញការងារដល់គ្រប់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ក្រុង
- បោះពុម្ព និងគ្រប់គ្រងរាល់ឯកសារ លិខិតស្នាមដែលទាក់ទងនឹងការងារជំនាញ និងការងាររដ្ឋបាលពន្ធដារ
- ត្រួតពិនិត្យការប្រើប្រាស់មូលនិធិ និងសម្ភារៈដែលទទួលបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រភពផ្សេងៗ ដើម្បីធានាឱ្យការប្រើប្រាស់មូលនិធិ និងសម្ភារៈទាំងនោះបានត្រឹមត្រូវ និងចំទិសដៅ
- កត់ត្រា និង រក្សាទុកបញ្ជីគណនេយ្យ និងលិខិតយុត្តិការផ្សេងៗដែលទាក់ទងនឹងចំណូល-ចំណាយ ឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលា
- គ្រប់គ្រងចលនទ្រព្យ និង អចលនទ្រព្យ សន្និធិសម្ភារៈ គ្រប់គ្រងការប្រើប្រាស់ ការរៀបចំជួសជុលសម្ភារៈបរិក្ខាររបស់អគ្គនាយកដ្ឋានពន្ធដារ ។

នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

មាត្រា ១៦.-

នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ មានភារកិច្ចដូចតទៅ÷

- រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិទាក់ទងនឹងបញ្ហាពន្ធដារ
- រៀបចំ និង លើកសំណើកែប្រែបំពេញបន្ថែមចំណុចខ្វះខាតក្នុងច្បាប់ អនុក្រឹត្យ ប្រកាស សារាចរស្តីពីពន្ធដារ
- រៀបចំឆ្លើយតបនឹងបញ្ហាទាំងឡាយទាក់ទងនឹងនីតិកម្មសារពើពន្ធ
- ចងក្រងច្បាប់ និងលិខិតបទដ្ឋាននានាស្តីពីពន្ធដារ ជាភាសាជាតិ និងភាសាបរទេស
- រៀបចំ និង ចូលរួមចរចាកិច្ចព្រមព្រៀង ដើម្បីជៀសវាងការយកពន្ធត្រួតគ្នាជាមួយបណ្តាប្រទេសនានា
- រៀបចំកិច្ចសហប្រតិបត្តិការសារពើពន្ធជាមួយអង្គការអន្តរជាតិ និងបណ្តាប្រទេសផ្សេងៗ
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងសេចក្តីណែនាំ ទំរង់លិខិតស្នាម និងព័ត៌មានផ្សេងៗ និងនីតិវិធីដោះស្រាយការតវ៉ា
- កសាងផែនការប្រចាំឆ្នាំ ស្តីពីការដោះស្រាយការតវ៉ា
- តាមដានការអនុវត្តគោលនយោបាយ និងលទ្ធផលពីកម្មវិធីដោះស្រាយការតវ៉ា
- ជួយក្នុងការកំណត់ការខ្វះខាត និងចំណុចខ្សោយនៃច្បាប់ស្តីពីពន្ធដារ
- គ្រប់គ្រងការតវ៉ាដែលកើតមានឡើងរវាងអ្នកជាប់ពន្ធ និងអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំសេចក្តីសំរេចរបស់អគ្គនាយក ឬសេចក្តីសំរេចទាំងឡាយសំរាប់ដាក់ជូនរដ្ឋមន្ត្រីទៅតាមសមត្ថកិច្ច
- ធានាទំនាក់ទំនងជាមួយនឹងតុលាការ
- ចងក្រងស្ថិតិ និងព័ត៌មានពីការដោះស្រាយការតវ៉ា ដើម្បីកំណត់លទ្ធផលពីការអនុវត្តកម្មវិធី
- រៀបចំរបាយការណ៍ព័ត៌មានស្តីពីការគ្រប់គ្រង
- កំណត់និន្នាការនៃការតវ៉ារបស់អ្នកជាប់ពន្ធ និងលទ្ធផលនៃការស្ទង់មតិ
- ប្រមូលផ្តុំរាល់ស្ថិតិតវ៉ាពាក់ព័ន្ធដល់មូលដ្ឋានកំណត់ពន្ធ

- រៀបចំកម្មវិធី និងបណ្តុះបណ្តាលមន្ត្រីវិវាទ
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រសារពើពន្ធ វិភាគ និងធ្វើការព្យាករណ៍ចំណូលពន្ធដារ សំរាប់រយៈពេលខ្លី មធ្យម វែង
- រៀបចំគោលនយោបាយយុទ្ធសាស្ត្រ និងបែបបទសំរាប់ធ្វើគណនេយ្យកម្មចំណូលពន្ធដារ ឬ សេចក្តីណែនាំនានាទាក់ទងនឹងការងារចាត់ចែងលិខិតប្រកាស
- តាមដានស្ថិតិអ្នកជាប់ពន្ធ ឬកសរុបព័ត៌មានពីគណនេយ្យចំណូលពន្ធដារ និងការចាត់ចែងលិខិតប្រកាសរបស់អ្នកជាប់ពន្ធ ក្នុងរបបស្វ័យប្រកាស និងរបបម៉ៅការ
- កសាងផែនការចំណូលពន្ធដារប្រចាំឆ្នាំតាមពេលកំណត់
- តាមដានលទ្ធផលអនុវត្តន៍បាន ប្រៀបធៀបនឹងផែនការចំណូលពន្ធដារប្រចាំឆ្នាំ
- រៀបចំរបាយការណ៍ព័ត៌មានស្តីពីការគ្រប់គ្រងប្រមូលពន្ធ
- រៀបចំ និងគ្រប់គ្រងឯកសារបោះពុម្ព និងកំណត់តំរូវការជាក់លាក់នានា ទាក់ទិននឹងទិន្នន័យពន្ធដារ
- អនុវត្តជាមួយថ្នាក់មូលដ្ឋាន ស្តីពីប្រព័ន្ធស្ថិតិ និងផែនការ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាល ស្ថិតិ និងផែនការ ដល់មន្ត្រីពន្ធដារ ។

នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ១៧.-**

នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយ និងកម្មវិធី ដើម្បីគាំទ្រដំណើរការសេវាជូនអ្នកជាប់ពន្ធ
- កសាងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងដោយប្រើប្រាស់ទំរង់បែបបទ ផ្តល់សេវាជូនអ្នកជាប់ពន្ធ
- កសាងយុទ្ធសាស្ត្រសេវាអ្នកជាប់ពន្ធ ដើម្បីធានាឱ្យអ្នកជាប់ពន្ធយល់អំពីកាតព្វកិច្ចសារពើពន្ធ និងការគោរពប្រតិបត្តិបទប្បញ្ញត្តិនានាស្តីពីពន្ធដារ

- ធ្វើការស្រាវជ្រាវដោយរួមបញ្ចូលការស្ទង់មតិលើបណ្តាបញ្ហា ដែលពាក់ព័ន្ធទៅនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ដើម្បីកំណត់នូវតម្រូវការព័ត៌មាន និងធ្វើការជ្រើសរើសសេវាកម្មល្អៗ ជូនអ្នកជាប់ពន្ធតាមផ្នែកនីមួយៗ
- រៀបចំ និងថែរក្សាសៀវភៅពន្យល់អំពីនីតិវិធីផ្ទៃក្នុងសំរាប់ការផ្តល់សេវាអ្នកជាប់ពន្ធ
- រៀបចំសិក្ខាសាលា អប់រំ ផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជាសាធារណៈ ស្តីពីប្រភេទពន្ធនីមួយៗ ដោយរួមបញ្ចូលទាំងការដាក់លិខិតប្រកាស ការបង់ប្រាក់ពន្ធ ការបំពេញសំណុំបែបបទ
- រៀបចំនិងផ្សព្វផ្សាយសៀវភៅមគ្គុទ្ទេសក៍ព័ត៌មានផ្សេងៗ ដូចជាប័ណ្ណពន្យល់ណែនាំ កូនសៀវភៅណែនាំ សំរាប់អ្នកជាប់ពន្ធប្រើប្រាស់
- ពិនិត្យឡើងវិញ និង ធ្វើអោយមានលក្ខណៈបច្ចុប្បន្នភាពនូវបណ្តាឯកសារព័ត៌មានដែលបានបោះពុម្ពផ្សព្វផ្សាយ ដើម្បីធានាថាព័ត៌មានទាំងនោះថ្មីៗ និងទាក់ទងគ្នា
- បង្កើតឡើងនូវគំរូលិខិតឆ្លើយតបជាលាយល័ក្ខអក្សរ និងតាមទូរស័ព្ទ ទូរសារ ក្នុងការឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធ ដើម្បីធានានូវសង្គតិភាព
- ចងក្រង និងបង្កើតតារាងទិន្នន័យអំពីបញ្ជីសំណួរដែលត្រូវបានលើកឡើងជារឿយៗ ដើម្បីជួយមន្ត្រីសេវាអ្នកជាប់ពន្ធ ក្នុងការរក្សានូវសង្គតិភាព និងគុណភាពនៅទូទាំងប្រទេសពេលដែលឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលជូនមន្ត្រីសេវាអ្នកជាប់ពន្ធ
- រៀបចំផែនការ និងកម្មវិធីសេវាអ្នកជាប់ពន្ធប្រចាំឆ្នាំ
- ត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងលទ្ធផលសំរេចបានពីកម្មវិធីសេវាអ្នកជាប់ពន្ធ
- បង្កើតឡើងនូវភាពជាដៃគូជាមួយក្រុមអ្នកជាប់ពន្ធ និងស្ថាប័នពាក់ព័ន្ធនានា
- អភិវឌ្ឍន៍នូវភាពជាក់លាក់តាមប្រព័ន្ធគេហទំព័រ ដែលទាក់ទងនិងសកម្មភាពសេវាអ្នកជាប់ពន្ធ
- បង្ហាញអោយឃើញនូវនិន្នាការនៃតម្រូវការរបស់អ្នកជាប់ពន្ធ តាមរយៈការចងក្រងការស្ទង់មតិ និងទិន្នន័យស្ថិតិ
- ធ្វើការសិក្សាស្រាវជ្រាវ ស្តីពីការគោរពប្រតិបត្តិរបស់អ្នកជាប់ពន្ធ ចំពោះការប្រមូលបំណុលពន្ធ និងបញ្ហាតឹងទារ និង ការអនុវត្តការប្រមូលបំណុលពន្ធ
- កសាងគោលនយោបាយ និងនីតិវិធីប្រមូលបំណុលសារពើពន្ធ និងវិធានការតឹងទារចំពោះអ្នកជាប់ពន្ធដែលមិនគោរពច្បាប់
- បង្កើនប្រសិទ្ធភាពនៃយុទ្ធសាស្ត្រប្រមូលបំណុលពន្ធ

- រៀបចំនីតិវិធី សេចក្តីណែនាំ គំរូលិខិតស្តីពីការប្រមូលបំណុលពន្ធ និងបណ្តុះបណ្តាល ស្តីពីការប្រមូលបំណុលពន្ធ
- កសាងផែនការប្រមូលបំណុលពន្ធប្រចាំឆ្នាំ
- កំណត់ និងជ្រើសរើសអ្នកជាប់បំណុលពន្ធជាអាទិភាព ដោយផ្អែកលើហានិភ័យ
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងកម្មវិធី ស្តីពីការប្រមូលបំណុលពន្ធ
- តាមដានលទ្ធផលនៃការអនុវត្តនូវគោលនយោបាយ និងកម្មវិធី ស្តីពីការប្រមូលបំណុលពន្ធ
- ជួយថ្នាក់មូលដ្ឋានក្នុងការប្រមូលបំណុលពន្ធ ចំពោះអ្នកជាប់ពន្ធដែលមានភាពស្មុគស្មាញ ឬមានទ្រង់ទ្រាយធំ
- កំណត់ចេញការអនុវត្តក្នុងការប្រមូលបំណុលពន្ធថ្មីដែលដំណើរការបានល្អ ហើយធានាឱ្យការអនុវត្តនេះ ត្រូវបានចែករំលែកដល់ផ្នែកប្រមូលបំណុលពន្ធដទៃទៀត
- ចងក្រងព័ត៌មានប្រតិបត្តិ ដែលទទួលបានពីថ្នាក់មូលដ្ឋាន
- រៀបចំរបាយការណ៍ព័ត៌មានអំពីការគ្រប់គ្រងបំណុលពន្ធ ដោយផ្អែកលើផែនការ និងការអនុវត្តបាន
- អភិវឌ្ឍន៍នូវភាពជាក់លាក់តាមប្រព័ន្ធកុំព្យូទ័រដែលទាក់ទងនឹងមុខងារ និង សកម្មភាពប្រមូលបំណុលពន្ធ
- កំណត់និន្នាការនៃការប្រមូលបំណុលពន្ធ ឥណទេយ្យ និងបំណុលភ្នំរ៉ៃ ។

នាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុលពន្ធ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ១៨.-**

នាយកដ្ឋានត្រួតពិនិត្យ មានភារកិច្ចដូចតទៅ÷

- តាមរយៈការធ្វើបេសកកម្មដល់ទីកន្លែង បំពេញមុខងារត្រួតពិនិត្យ អង្កេត និងប្រមូលផ្តុំព័ត៌មានអំពីការគ្រប់គ្រងប្រមូលពន្ធគ្រប់នាយកដ្ឋាន គ្រប់សាខាពន្ធដារខេត្ត-ក្រុង និងគ្រប់ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារសំរាប់ជាជំនួយ ក្នុងការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ

- គ្រប់នាយកដ្ឋាន សាខាពន្ធដារខេត្ត-ក្រុង ការិយាល័យពន្ធដារខ័ណ្ឌ នៃរាជធានីភ្នំពេញ អាចស្នើមកអគ្គនាយកដ្ឋាន ឱ្យនាយកដ្ឋាននេះ ធ្វើអន្តរាគមន៍នៅក្នុងវិស័យនានា ក្រោមសមត្ថកិច្ចរបស់ខ្លួន
- នាយកដ្ឋានត្រួតពិនិត្យ មានភារកិច្ចរាយការណ៍ជាលាយលក្ខណ៍អក្សរ ជាប្រចាំអំពីលទ្ធផលការងាររបស់ខ្លួនជូនអគ្គនាយកដ្ឋានពន្ធដារ ។

នាយកដ្ឋានត្រួតពិនិត្យ ដឹកនាំដោយប្រធានម្នាក់ និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ១៩.-**

នាយកដ្ឋានព័ត៌មានវិទ្យា មានភារកិច្ចដូចតទៅ÷

- អភិវឌ្ឍន៍យុទ្ធសាស្ត្រព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋានពន្ធដារ
- សហការជាមួយនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ក្រុងពាក់ព័ន្ធ ក្នុងការពង្រឹងការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីឱ្យផ្នែកពាក់ព័ន្ធប្រើប្រាស់ទិន្នន័យនេះមានប្រសិទ្ធភាព
- កសាងគោលនយោបាយ និងនីតិវិធីព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋានពន្ធដារ
- រៀបចំសេចក្តីណែនាំ បទដ្ឋាន និងទំរង់លិខិតស្នាម ស្តីពីព័ត៌មានវិទ្យា
- រៀបចំ និងថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធសុវត្ថិភាព ផ្នែកព័ត៌មានវិទ្យា
- ថែរក្សាប្រតិបត្តិការ នៃប្រព័ន្ធព័ត៌មានវិទ្យា រួមបញ្ចូលគ្នា ទាំងក្នុងរបបស្វ័យប្រកាស ទាំងក្នុងរបបម៉ៅការ
- តាមដានការអនុវត្តកម្មវិធីស្តីពីព័ត៌មានវិទ្យា
- បង្កើតកម្មវិធីថ្មីសំរាប់ផ្លាស់ប្តូរ
- រៀបចំរបាយការណ៍ស្តីពីការគ្រប់គ្រងព័ត៌មានវិទ្យា
- ជួយអភិវឌ្ឍន៍នូវការកំណត់មុខងារឱ្យបានច្បាស់លាស់ សំរាប់ប្រើប្រាស់ក្នុងប្រព័ន្ធព័ត៌មានវិទ្យា ចំពោះគ្រប់កម្មវិធី ដែលបានដាក់ចេញ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលព័ត៌មានវិទ្យា ។

នាយកដ្ឋានព័ត៌មានវិទ្យា ដឹកនាំដោយប្រធានម្នាក់ និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

**មាត្រា ២០.-**

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ មានភារកិច្ចដូចតទៅ÷

- ទទួលខុសត្រូវក្នុងការគ្រប់គ្រងអ្នកជាប់ពន្ធធំទូទាំងប្រទេស ដែលស្ថិតក្នុងប្រព័ន្ធប្រមូលពន្ធតាមរបបពិត ដែលជាប្រព័ន្ធឆ្លើយប្រកាសដោយអ្នកជាប់ពន្ធខ្លួនឯង
- ចុះបញ្ជីអ្នកជាប់ពន្ធ និងចេញវិញ្ញាបនបត្រចុះបញ្ជីតាមប្រភេទពន្ធនានាដែលតម្រូវដោយច្បាប់ ចេញប័ណ្ណប៉ាតង់ កាន់កាប់ថែរក្សាបញ្ជីអ្នកជាប់ពន្ធ និងកត់ត្រារាល់ការផ្លាស់ប្តូរព័ត៌មានអ្នកជាប់ពន្ធ
- ផ្តល់សេវាជូនអ្នកជាប់ពន្ធ រួមមាន ការផ្តល់ប្រឹក្សា ការដោះស្រាយចម្ងល់ផ្សេងៗ ការផ្តល់ទំរង់លិខិតប្រកាស សារពើពន្ធ និងលិខិតបទដ្ឋាននានាទាក់ទងនឹងពន្ធដារ
- ចូលរួមរៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មាន ដែលពាក់ព័ន្ធនឹងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និង អនុវត្តកម្មវិធីអប់រំ បណ្តុះបណ្តាល ដើម្បីជួយអ្នកជាប់ពន្ធឱ្យយល់នូវកាតព្វកិច្ចសារពើពន្ធ
- ពង្រឹងការបញ្ចូលទិន្នន័យក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីធានាការប្រើប្រាស់ព័ត៌មានរបស់អ្នកជាប់ពន្ធ
- ទទួលនិងពិនិត្យភាពត្រឹមត្រូវនៃលិខិតប្រកាសសារពើពន្ធ ដើម្បីធានាថាលិខិតប្រកាសត្រូវបានបំពេញគ្រប់ខ្ទង់ គ្រប់និទ្ទេស និងការគណនាឱ្យបានត្រឹមត្រូវ
- រៀបចំ និងរក្សាទុកសំណុំឯកសារលិខិតប្រកាសរបស់អ្នកជាប់ពន្ធ និងពិនិត្យលើភាពមិនប្រក្រតីនៃលិខិតប្រកាស ដើម្បីធ្វើសវនកម្មលើលិខិតស្នាម ឬលើកសំណើធ្វើសវនកម្ម
- ផ្ទៀងផ្ទាត់ការបង់ប្រាក់ពន្ធជាមួយនឹងប្រកាសឥណទាន ប្រកាសឥណពន្ធ និងរបាយការណ៍សមតុល្យគណនី ដែលទទួលបានពីធនាគារជាតិនៃកម្ពុជា
- បញ្ចូលទិន្នន័យនៃការប្រមូលចំណូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ដើម្បីធ្វើគណនេយ្យកម្មចំណូលសារពើពន្ធ រួមមាន ការធ្វើសលាកបត្របង់ប្រាក់ចូលថវិកាជាតិ . និងធ្វើរបាយការណ៍ជូនអគ្គនាយកដ្ឋានពន្ធដារ
- ចូលរួមកសាង និងអនុវត្តកម្មវិធីសវនកម្ម ដែលរួមមានសវនកម្មលើឯកសារ សវនកម្មតាមប្រភេទពន្ធ និងសវនកម្ម ចំពោះអ្នកជាប់ពន្ធក្នុងមួយរយៈពេលកំណត់ពន្ធ ដើម្បីឱ្យអ្នកជាប់ពន្ធគោរពប្រតិបត្តិតាមច្បាប់ស្តីពីសារពើពន្ធ
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ
- ធ្វើសវនកម្មអ្នកជាប់ពន្ធ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់នាយកដ្ឋានឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលាស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកម្មវិធីសវនកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ

- កំណត់បញ្ហា ដើម្បីកែលំអគោលនយោបាយ ផែនការ កម្មវិធីសវនកម្ម និងការជ្រើសរើសអ្នកជាប់ពន្ធ
- កំណត់តម្រូវការលើការបណ្តុះបណ្តាលទូទៅ និងលើការលំបាកក្នុងការធ្វើសវនកម្ម
- អនុវត្តន៍គោលនយោបាយ និងកម្មវិធីក្នុងការប្រមូលបំណុលពន្ធ និងអនុវត្តវិធានការតឹងទារបំណុលពន្ធ-ប្រមូលទិន្នន័យពីគ្រប់ប្រភព ដើម្បីវាស់ស្ទង់អោយបានល្អនូវប្រសិទ្ធភាព និងគុណភាពនៃការអនុវត្តវិធានការតឹងទារបំណុលពន្ធ
- អនុវត្តន៍ការលើកលែងការឃុំគ្រង ឬបញ្ចេញទ្រព្យសម្បត្តិដែលបានរឹបអូស ស្របទៅតាមនីតិវិធី និងគោលនយោបាយ របស់អគ្គនាយកដ្ឋានពន្ធដារ ។

នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា ២១ . -**

នាយកដ្ឋានសវនកម្មសហគ្រាស មានភារកិច្ចដូចតទៅ ÷

- ធ្វើសវនកម្មទូទៅ រួមមាន សវនកម្មពេញលេញលើគ្រប់ប្រភេទពន្ធ និងគ្រប់អ្នកជាប់ពន្ធធំក្នុងទូទាំងប្រទេស
- រៀបចំរចនាសម្ព័ន្ធសំរាប់គាំទ្រ កម្មវិធី យុទ្ធសាស្ត្រ អាទិភាព និង គោលដៅនានា នៃសវនកម្មជាតិ
- ចូលរួមកសាង កំណត់គោលដៅអាទិភាព និងអនុវត្តកម្មវិធីសវនកម្ម
- កំណត់ចេញនូវលទ្ធផលដែលនឹងត្រូវសំរេច ដោយផ្អែកលើកម្មវិធីសវនកម្ម និងការបែងចែកសវនករ
- សំរបសំរួលជាមួយថ្នាក់មូលដ្ឋាន ដែលទាក់ទងនឹងការគ្រប់គ្រងព័ត៌មានរបស់សហគ្រាសដែលត្រូវធ្វើសវនកម្ម
- គ្រប់គ្រងករណីរសើបជាមួយនឹងថ្នាក់កណ្តាល
- កំណត់បញ្ហាដើម្បីកែលំអការអភិវឌ្ឍនូវគោលនយោបាយសវនកម្ម កម្មវិធីសវនកម្មនិងប្រព័ន្ធសវនកម្ម
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកម្មវិធីសវនកម្មប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំផែនការសវនកម្មលើសំណុំឯកសារនីមួយៗ និងពិនិត្យសំណុំឯកសារឡើងវិញ ដើម្បីរកឱ្យឃើញបញ្ហាដែលពាក់ព័ន្ធនឹងសំណុំឯកសារទាំងនោះ

- ផ្តល់លទ្ធផលនៃការកំណត់ពន្ធឡើងវិញលើអ្នកជាប់ពន្ធទៅថ្នាក់មូលដ្ឋានដែលពាក់ព័ន្ធ
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលសវនករ ។

ពិនិត្យឡើងវិញរាល់ការងារសវនកម្ម ស្របតាមកម្មវិធីសវនកម្ម ដើម្បីធានានូវគុណភាព និងភាពត្រឹមត្រូវនៃការកំណត់ពន្ធឡើងវិញ ស្របតាមគោលនយោបាយសវនកម្ម និងវាយតំលៃលទ្ធផលការងាររបស់សវនករ ព្រមទាំងរៀបចំតម្រូវការបណ្តុះបណ្តាលសវនករ ។

នាយកដ្ឋានសវនកម្មសហគ្រាស ដឹកនាំដោយប្រធានមួយរូប និង មានអនុប្រធានមួយចំនួន ជាជំនួយការ ។

## ផ្នែកទី៣

## អគ្គនាយកដ្ឋានរតនាគារជាតិ

**មាត្រា ២២.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានបេសកកម្មដូចតទៅ÷

- ជាបេឡាករ និងជាគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ និងគណនីពិសេសនៃរតនាគារ
- រៀបចំគោលការណ៍ និងបទបញ្ញាគណនេយ្យសាធារណៈ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- ធានាតុល្យភាពទូទៅនៃគណនី
- តំរង់ទិស និងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ
- សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- កសាងសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**មាត្រា ២៣.-**

អគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រងបេឡាថវិកាថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន និងថវិកាស្វយ័ត
- គ្រប់គ្រងគណនីរបស់ក្រសួងស្ថាប័នថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន គណនីប្រាក់បញ្ញើឯកជន គណនីក្រៅថវិកា និងគណនីពិសេសរបស់រតនាគារ
- គ្រប់គ្រងប្រាក់កាសរបស់រដ្ឋ មូលបត្ររដ្ឋ និងសញ្ញាប័ណ្ណរដ្ឋ
- ធ្វើតុល្យភាពសាច់ប្រាក់ និងគ្រប់គ្រងចំណូល-ចំណាយថវិកាជាតិ
- រួមចំណែកក្នុងការតំរង់ទិសការអនុវត្តគោលនយោបាយរូបិយវត្ថុ

- តំរង់ទិស និងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ
- កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី
- រៀបចំគោលការណ៍ និងបិទបញ្ជីគណនេយ្យសាធារណៈ
- ធានាតុល្យភាពទូទៅនៃគណនី
- ផ្តល់សេវាដល់គ្រប់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល និង រដ្ឋបាលថ្នាក់មូលដ្ឋាន លើការទូទាត់ការចំណាយផ្សេងៗ ការបើកបៀវត្សរ៍ និង ការប្រមូលចំណូលស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- ធ្វើទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ
- ចូលរួមរៀបចំគំរោងថវិកាជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ
- កសាងសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

អគ្គនាយកដ្ឋានរតនាគារជាតិ ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការ ។

**មាត្រា ២៤. -**

រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរតនាគារជាតិនៅថ្នាក់កណ្តាល មាននាយកដ្ឋានចំនួន ៦ អធិការកិច្ចរតនាគារ លេខាធិការដ្ឋាន និងនៅថ្នាក់មូលដ្ឋាន មានរតនាគារខេត្ត-ក្រុង ។

**ក. ថ្នាក់កណ្តាល ÷**

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានចំណូល និងចំណាយថវិកា
- នាយកដ្ឋានគណនេយ្យ
- នាយកដ្ឋានគ្រប់គ្រងបេឡា និងបំណុល
- នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ
- នាយកដ្ឋានពត៌មានវិទ្យា
- អធិការកិច្ចរតនាគារ (ថ្នាក់ស្មើនាយកដ្ឋាន)
- លេខាធិការដ្ឋាន (ថ្នាក់ស្មើការិយាល័យ)។

២. ថ្នាក់មូលដ្ឋាន ÷

នៅថ្នាក់មូលដ្ឋាន មានរតនាគារខេត្ត-ក្រុង ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើអនុប្រធាននាយកដ្ឋាន នៅថ្នាក់កណ្តាល និង មានអនុប្រធានមួយចំនួនជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យ នៅថ្នាក់កណ្តាល។

រតនាគារខេត្ត-ក្រុងនីមួយៗ មានការិយាល័យក្រោមឱវាទ ចំនួន ៣ះ

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យគណនេយ្យ
- ការិយាល័យបេឡា។

អង្គការលេខរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ជាឧបសម្ព័ន្ធទី៣ នៃអនុក្រឹត្យនេះ ។

មាត្រា ២៥. -

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក មានភារកិច្ចដូចតទៅ÷

- រៀបចំ និងតាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុង
- បញ្ជូនឯកសារ ទទួលលិខិតចេញ-ចូល និងរៀបចំចងក្រងទុកដាក់ឯកសារ
- ពិនិត្យទិដ្ឋាការបេសកកម្មចេញ-ចូល និង តាមដានគ្រប់គ្រងប្រាក់បេសកកម្ម
- គ្រប់គ្រងអចលនទ្រព្យ ចលនទ្រព្យ ការងារសន្តិសុខ និងសណ្តាប់ធ្នាប់
- បញ្ជិកាតាមដានប្រាក់ជំពូក-គណនី-អនុគណនីសំរាប់កិច្ចដំណើរការរដ្ឋបាល
- គ្រប់គ្រង បែងចែក បើកផ្តល់ប្រាក់លាភការ ប្រាក់បៀវត្សរ៍ និងសំភារៈការិយាល័យ
- គ្រប់គ្រងមន្ត្រីរាជការ-កម្មករអណ្តែត
- រៀបចំរចនាសម្ព័ន្ធចាត់តាំង-អង្គការលេខ។

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

មាត្រា ២៦. -

នាយកដ្ឋានចំណូល និងចំណាយថវិកា មានភារកិច្ចដូចតទៅ÷

- គ្រប់គ្រង និងតាមដានចំណូលសារពើពន្ធ និង ប្រមូលចំណូលមិនមែនសារពើពន្ធ
- ទទួលចំណូលប្រាក់ជំពាក់ ប្រាក់បំណុលរបស់រដ្ឋ និងប្រាក់វិភាគ
- បញ្ជិកាប្រាក់ពន្ធជាបន្ទុករបស់រដ្ឋ ប្រាក់ជំពាក់ ចំណូលថវិកាថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- គ្រប់គ្រងគណនីរដ្ឋទេយ្យចំណូល-គណនីចំណូលបណ្តោះអាសន្នរបស់គយ-ពន្ធដារ
- ពិនិត្យបញ្ជាក់អាណត្តិបើកប្រាក់ និងលិខិតយុត្តិការភ្ជាប់តាមអាណត្តិបើកប្រាក់

- ពិនិត្យឥណទានទំនេររបស់ក្រសួង-ស្ថាប័ន
- បញ្ជិកាតាមដានប្រាក់បុរេប្រទាន-រជ្ជទេយ្យបុរេប្រទាន និងចំណាយតាមកិច្ចសន្យា
- ចុះកិច្ចបញ្ជិកាតាមដានលំអិតចំណូល-ចំណាយថវិកាថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន ជាប្រាក់រៀល និង ប្រាក់រូបិយប័ណ្ណបរទេស
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ-ខែ-ត្រីមាស និងឆ្នាំ។

នាយកដ្ឋានចំណូល និងចំណាយថវិកា ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

**មាត្រា ២៧.-**

នាយកដ្ឋានគណនេយ្យ មានភារកិច្ចដូចតទៅៈ
- និយ័តភាពសាច់ប្រាក់រវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ទទួលពិនិត្យ និងប្រមូលផ្តុំសលាកប័ត្រ-លេខនា-សក្ខីប័ត្រគណនេយ្យ
- រៀបចំតារាងតុល្យភាព និង តារាងតុល្យការទូទាំងប្រទេស (ថវិកាថ្នាក់កណ្តាល និងថវិកាថ្នាក់មូលដ្ឋាន)
- រៀបចំគោលការណ៍ និងបទបញ្ជាគណនេយ្យសាធារណៈ
- គ្រប់គ្រងគណនីប្រាក់បញ្ញើរបស់ក្រសួង-ស្ថាប័ន និងអង្គភាពស្វយ័ត
- គ្រប់គ្រងគណនីប្រាក់កក់ធានា និងគណនីប្រាក់បញ្ញើផ្សេងៗ
- គ្រប់គ្រងគណនីជាប្រាក់រៀល និងប្រាក់រូបិយប័ណ្ណបរទេស គណនីជំនួយទ្រទ្រង់ថវិកាជាតិ និងគណនីពិសេសផ្សេងៗទៀត
- ធ្វើការទូទាត់អាណត្តិបើកប្រាក់
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ-ខែ-ត្រីមាស និងឆ្នាំ។

នាយកដ្ឋានគណនេយ្យ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

**មាត្រា ២៨.-**

នាយកដ្ឋានគ្រប់គ្រងបេឡា និងបំណុល មានភារកិច្ចដូចតទៅៈ
- ធ្វើប្រតិបត្តិការចំណូល-ចំណាយសាច់ប្រាក់
- ប្រគល់-ទទួលសាច់ប្រាក់និយ័តកម្មរវាងថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ធ្វើការផ្ទៀងផ្ទាត់តួលេខក្នុងឯកសារនៃកិច្ចប្រតិបត្តិការជាមួយនឹងសាច់ប្រាក់ជាក់ស្តែង ដែលមាននៅក្នុងឃ្លាំងបេឡាប្រចាំថ្ងៃ
- ទទួល និងថែរក្សាមូលបត្ររដ្ឋ-សញ្ញាប័ណ្ណរដ្ឋ

- គ្រប់គ្រង លក់ និងសងបំណុលមូលបត្ររដ្ឋ
- បញ្ជិកាចំណូល-ចំណាយនៃកិច្ចប្រតិបត្តិការនៃការលក់មូលបត្ររដ្ឋ
- បញ្ជិកាបំណុល
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ-ខែ-ត្រីមាស-ឆ្នាំ។

នាយកដ្ឋានបេឡា និងបំណុល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

**មាត្រា ២៩.-**

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ មានភារកិច្ចដូចតទៅៈ

- ពិនិត្យតាមដានកិច្ចដំណើរការរបស់រតនាគារថ្នាក់មូលដ្ឋាន
- ពិនិត្យការផ្ទេរមូលនិធិពីថ្នាក់កណ្តាលទៅថ្នាក់មូលដ្ឋាន និងពីថ្នាក់មូលដ្ឋានមកថ្នាក់កណ្តាល
- ពិនិត្យតុល្យភាពសាច់ប្រាក់ និងតាមដានចំណូល-ចំណាយរបស់រតនាគារថ្នាក់មូលដ្ឋាន
- សំរបសំរួលរាល់ការងារពាក់ព័ន្ធរវាងរតនាគារថ្នាក់មូលដ្ឋានជាមួយបណ្តានាយកដ្ឋានជំនាញថ្នាក់កណ្តាលនៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រមូលផ្តុំព័ត៌មានគណនេយ្យ និងស្ថិតិ ដែលបានមកពីនាយកដ្ឋានថ្នាក់កណ្តាល និងរតនាគារថ្នាក់មូលដ្ឋាន
- ធ្វើរបាយការណ៍ប្រចាំថ្ងៃ-ខែ-ត្រីមាស-ឆ្នាំ។

នាយកដ្ឋានគ្រប់គ្រងរតនាគារថ្នាក់មូលដ្ឋាន និងសរុបស្ថិតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

**មាត្រា ៣០.-**

នាយកដ្ឋានព័ត៌មានវិទ្យា មានភារកិច្ចដូចតទៅ÷

- អភិវឌ្ឍន៍យុទ្ធសាស្ត្រ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- កសាងគោលនយោបាយ និងនីតិវិធីព័ត៌មានវិទ្យា
- រៀបចំ ថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធសុវត្ថិភាព ផ្នែកព័ត៌មានវិទ្យា
- គ្រប់គ្រងកិច្ចសន្យាដែលបានធ្វើជាមួយអ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់
- វិភាគមុខងារអំពីតំរូវការតាមផ្នែក
- រៀបចំរបាយការណ៍ និងតាមដានការអនុវត្តកម្មវិធីស្តីពីព័ត៌មានវិទ្យា
- រៀបចំកម្មវិធី និងបណ្តុះបណ្តាលព័ត៌មានវិទ្យាដល់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។

នាយកដ្ឋានព័ត៌មានវិទ្យា ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

មាត្រា ៣១.-

អធិការកិច្ចរតនាគារ មានភារកិច្ចដូចតទៅ:

- តាមដាន ត្រួតពិនិត្យការប្រព្រឹត្តិទៅនៃរតនាគារទូទាំងប្រទេស
- ពិនិត្យបញ្ជាក់លំអិតនូវបញ្ជិកាគណនេយ្យនិងបេឡានៃរតនាគារថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ចូលរួមសហការជាមួយអគ្គាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើការត្រួតពិនិត្យរតនាគារ ក្នុងករណីសំណូមពរអោយចូលរួម
- ទទួលពាក្យបណ្តឹងតវ៉ា និងចូលរួមដោះស្រាយនូវរាល់បាតុភាពខុសឆ្គងរបស់មន្ត្រីរាជការ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យរបស់ខ្លួន។

អធិការកិច្ចរតនាគារ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ។

## ផ្នែកទី៤

## បទប្បញ្ញត្តិរួម

មាត្រា ៣២.-

ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី៣

## អន្តរប្បញ្ញត្តិ

មាត្រា ៣៣.-

អគ្គនាយកនៃអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃអគ្គនាយកពន្ធដារ និង អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវសំរបសំរួលការងារជាមួយនឹងអគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាបាននូវ និរន្តរភាព សង្គតិភាព និង ប្រសិទ្ធភាព ក្នុងការបំពេញបេសកកម្ម និងក្នុងការអនុវត្តភារកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៤.-

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវផ្តល់កិច្ចសម្របសម្រួលការងារ ជាមួយនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាបាននូវសង្គតិភាព និង ប្រសិទ្ធភាពការងារនៃការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ចំលងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
  នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង និង រាជធានីភ្នំពេញ
- ដូចមាត្រា ៣៦
- ឯកសារ- កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨

## អង្គការលេខរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា



ឧបសម្ព័ន្ធទី២នៃអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៨

## អង្គភាពលេខរបស់អគ្គនាយកដ្ឋានពន្ធដារ



ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨

អង្គភាពលេខរបស់អគ្គនាយកដ្ឋានរតនាគារជាតិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ៦០៩ សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៦

# ប្រកាស
## ស្ដីពី
## ការបង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ

*** ៚ ***

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ករត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ បក ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ
- យោងសេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ ៩០ សជណ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៥
- យោងស្មារតីនៃអង្គប្រជុំបើកទូលាយ របស់គណៈកម្មាធិការដឹកនាំដើម្បីអភិវឌ្ឍន៍ផ្នែកឯកជននាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្ដីពីយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ
- យោងតាមតម្រូវការ និងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

136.

# សំរេច

<u>ប្រការ ១</u>: បង្កើត និងដាក់ឱ្យដំណើរការនូវការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ទីចាត់ការគយនិងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

<u>ប្រការ ២</u>: ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។

<u>ប្រការ ៣</u>: ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានតួនាទីដូចតទៅ ÷

១- កសាង និងអនុវត្តនូវកម្មវិធីគ្រប់គ្រងហានិភ័យ សំរាប់ទីចាត់ការគយនិងរដ្ឋាករ ដោយឈរលើគោលការណ៍នៃកិច្ចសម្រួលពាណិជ្ជកម្ម ក្នុងពេលជាមួយនឹងការការពារចំណូលពន្ធនិងអាករ ការត្រួតពិនិត្យចរាចរទំនិញខុសច្បាប់ ឬទំនិញរត់ពន្ធ និងចូលរួមពង្រឹងនូវសន្តិសុខនៃការនាំចេញ និងនាំចូល។

២- ជំរុញឱ្យអង្គភាពគយនិងរដ្ឋាករនានា អនុវត្តនូវគោលការណ៍នៃការគ្រប់គ្រងហានិភ័យ និងការជ្រើសរើសមុខសញ្ញាក្នុងប្រតិបត្តិការរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដោយគ្រប់គ្រង ត្រួតពិនិត្យ និងវាយតំលៃកិច្ចការទាំងនេះ។

៣- ជូនយោបល់ដល់ថ្នាក់ដឹកនាំទីចាត់ការគយនិងរដ្ឋាករ ពីការវិវត្តនៃកម្មវិធីគ្រប់គ្រងហានិភ័យ និងរៀបចំជារបាយការណ៍ និងការវិភាគ អនុលោមតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ។

៤- ធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ លើអាជីវករ ឬបុគ្គលពាក់ព័ន្ធ ដោយផ្អែកលើហានិភ័យដែលបានរកឃើញ។

៥- អនុវត្តនូវមុខងារ និងភារកិច្ចនានាដូចមានចែងក្នុងប្រការ ១១ នៃប្រកាសលេខ ៩២០ សហវ គរ ប្រក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីចាត់ការគយនិងរដ្ឋាករ។

៦- ប្រើប្រាស់កំលាំងគយនិងរដ្ឋាករក្រោមឱវាទ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ក្នុងករណីចាំបាច់ ដើម្បីសំរេចឱ្យបាននូវតួនាទីដូចរៀបរាប់ខាងលើ។

<u>ប្រការ ៤</u>: ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានសិទ្ធិដូចតទៅ ÷

១- ធ្វើជាចំណុចទំនាក់ទំនងតែមួយរបស់ទីចាត់ការគយនិងរដ្ឋាករ ជាមួយភ្នាក់ងារ ឬអង្គភាពផ្សេងទៀត ដើម្បីទំនាក់ទំនងផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធនឹងទំនិញ មធ្យោបាយដឹកជញ្ជូន និងមុខសញ្ញាដែលមានហានិភ័យខ្ពស់ចំពោះអង្គភាពគយនិងរដ្ឋាករ តាមរយៈ ÷

- ការទំនាក់ទំនងស្រាវជ្រាវរកឯកសារ និងព័ត៌មាននានា ពីបណ្តាអង្គភាពក្រោមឱវាទទីចាត់ការគយនិងរដ្ឋាករ ហើយក្នុងករណីចាំបាច់ តំរូវឱ្យអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធផ្តល់ព័ត៌មានជាប្រចាំតាមទំរង់ជាក់លាក់ ដែលយល់ថាមានប្រយោជន៍។

- ការទំនាក់ទំនងស្រាវជ្រាវរកឯកសារ និងផ្តល់ឯកសារមួយចំនួនទៅវិញទៅមកជាមួយនឹងភ្នាក់ងារ ឬអង្គភាពជំនាញនៃក្រសួង ឬស្ថាប័នមានសមត្ថកិច្ចនានានៃរាជរដ្ឋាភិបាល ដោយមានការអនុញ្ញាតជាមុនពីទីចាត់ការគយនិងរដ្ឋាករ។
- ការទទួលព័ត៌មាន និងឯកសារនានាពីភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ផ្នែកឯកជន និងរដ្ឋបាលគយបរទេស ពាក់ព័ន្ធនឹងការនាំចេញនាំចូលទំនិញ ដើម្បីសំណូមពរនៃការកំណត់ហានិភ័យ ដោយមានការអនុញ្ញាតជាមុនពីទីចាត់ការគយនិងរដ្ឋាករ។

២- ចេញសេចក្តីណែនាំតម្រង់ទិសដល់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធនានាពីមុខសញ្ញាទំនិញ, និងមធ្យោបាយដឹកជញ្ជូនដែលត្រូវត្រួតពិនិត្យដោយគយ ពីកំរិតនៃការត្រួតពិនិត្យទំនិញដោយផ្អែកលើការវាយតំលៃហានិភ័យ ហើយអាចចាត់តាំងមន្ត្រីក្រោមឱវាទចូលរួមដោយផ្ទាល់ក្នុងការត្រួតពិនិត្យទំនិញដែលស្ថិតក្នុងមុខសញ្ញាហានិភ័យនោះ។

៣- បញ្ជូនមន្ត្រីមួយចំនួននៃការិយាល័យនេះទៅបំពេញភារកិច្ចនៅតាមអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ ដើម្បីកំណត់ទិសដៅ និងអនុវត្តនូវការគ្រប់គ្រងហានិភ័យ ក្នុងករណីយល់ថាចាំបាច់។

៤- ប្រមូលផ្តុំ និងផ្ទៀងផ្ទាត់នូវលទ្ធផលនៃការត្រួតពិនិត្យទំនិញ និងការអនុវត្តផែនការនានានៃការគ្រប់គ្រងហានិភ័យ។

៥- ប្រមូលពន្ធអាករ ឬប្រាក់ពិន័យបើមាន ពីលទ្ធផលការងារសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ ដែលស្ថិតក្នុងមុខសញ្ញាហានិភ័យ និងមានសិទ្ធិទទួលនូវប្រាក់រង្វាន់ ស្របតាមខ្លឹមសារប្រកាសស្តីពីការបែងចែកផលដែលបានមកពីប្រតិបត្តិការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ និងបទបញ្ញត្តិផ្សេងទៀតជាធរមាន។

៦- គ្រប់គ្រងការចេញ និងត្រួតពិនិត្យការអនុវត្ត "លិខិតបញ្ជា" របស់ទីចាត់ការគយនិងរដ្ឋាករឱ្យឃាត់ទុកជាបណ្តោះអាសន្ន ឱ្យត្រួតពិនិត្យលំអិត ឬឱ្យត្រួតពិនិត្យឡើងវិញតាមមុខសញ្ញាទំនិញ មធ្យោបាយដឹកជញ្ជូន និងអាជីវកម្មដ្ឋាន ឬលំនៅស្ថានដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើសគយ ស្របតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។

ប្រការ ៥: ការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ មានភារកិច្ចដូចតទៅ :

១- កសាងផែនការគ្រប់គ្រងហានិភ័យលំអិត ដើម្បីកំណត់មុខទំនិញ មធ្យោបាយដឹកជញ្ជូននានា ឆ្លងកាត់មាត់ច្រកព្រំដែន និងមុខសញ្ញាដែលមានហានិភ័យខ្ពស់។

២- តាមដានអនុវត្តកិច្ចព្រមព្រៀងអន្តរស្ថាប័នជាមួយនឹងភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត ដោយអនុលោមតាមអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ដោយសម្របសម្រួលការងាររវាងទីចាត់ការគយនិងរដ្ឋាករ និងស្ថាប័នឯកទេសនានា។

៣- សហការជាមួយភ្នាក់ងារ ឬអង្គភាពជំនាញនៃក្រសួង ឬស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងហានិភ័យ រាប់បញ្ចូលទាំងការងារផ្លាស់ប្តូរព័ត៌មាន និងការផ្តល់នូវជំនួយទៅវិញទៅមក។

៤- ជួយការិយាល័យ និងសាខាគយនិងរដ្ឋាករនានា រៀបចំនូវផែនការប្រតិបត្តិនៃការគ្រប់គ្រងហានិភ័យ។

៥- កសាងកម្មវិធី និងផ្តល់នូវការហ្វឹកហ្វឺនដល់ភ្នាក់ងារគយនិងរដ្ឋាករ អំពីការគ្រប់គ្រងហានិភ័យ។

៦- កសាង និងកាន់កាប់នូវបញ្ជីទំនិញហាមឃាត់ ឬដាក់កំរិតកំណត់ ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ ASYCUDA និងសំរាប់ចែកចាយដល់គ្រប់អង្គភាពគយនិងរដ្ឋាករ និងផ្តល់នូវការណែនាំ ថាតើទំនិញទាំងនេះ នឹងត្រូវផ្តល់ប្រព្រឹត្តកម្មដូចម្តេច ដោយមន្ត្រីគយនិងរដ្ឋាករ។

៧- កសាង និងកាន់កាប់នូវទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ រួមមានការកត់ត្រាលើកំណត់ហេតុបទល្មើសគយ ព័ត៌មានពីមុខសញ្ញាសង្ស័យថាជាអ្នករត់ពន្ធ ឬជាអ្នករំលោភច្បាប់ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត។

៨- ប្រមូល និងវិភាគព័ត៌មានពីប្រភពនានា ចាត់ចែងវិភាគហានិភ័យ កសាងមុខសញ្ញាហានិភ័យ និងលក្ខណៈវិនិច្ឆ័យជ្រើសរើស និងមុខសញ្ញាដោយឡែកនានា និងផ្សព្វផ្សាយដល់អង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ។

៩- គ្រប់គ្រង តាមដាន និងវាយតំលៃការអនុវត្តនូវផែនការគ្រប់គ្រងហានិភ័យដោយអង្គភាពគយនិងរដ្ឋាករពាក់ព័ន្ធ។

១០- ពាក់តែងរបាយការណ៍នានា ដែលជាមូលដ្ឋាននៃការវាយតំលៃប្រសិទ្ធភាពនៃការអនុវត្តការគ្រប់គ្រងហានិភ័យនៅទីចាត់ការគយនិងរដ្ឋាករ។

១១- កសាង និងអនុវត្តផែនការសវនកម្មផ្ទៃក្នុងអង្គភាពគយនិងរដ្ឋាករ និងចាត់ចែងធ្វើសវនកម្មក្រោយការបញ្ចេញទំនិញពីគយ លើមុខសញ្ញាហានិភ័យនានា។

១២- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ទីចាត់ការគយនិងរដ្ឋាករ។

<u>ប្រការ ៦</u>: ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

<u>ប្រការ ៧</u>: ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

គាត ឈន់

<u>កន្លែងទទួល</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាមីភាគីក្នុងក្រសួងដែលពាក់ព័ន្ធ
"ដើម្បីជូនជ្រាប និងសុំកិច្ចសហការអនុវត្ត"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ